KPI 0498

**សម្ភាសន៍ជាមួយឈ្មោះ យ៉ែម សំអុន ភេទប្រុស អាយុ៦០ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ «បច្ចេកទេសនារីវ៉ា»**

**មុខងារបច្ចុប្បន្នៈ លក់ដូរ**

**ស្រុកកំណើតនៅភូមិកល់គម ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ**

**សព្វថ្ងៃរស់នៅភូមិពងទឹក ឃុំស្រែចែង ស្រុកជុំគីរី ខេត្តកំពត**

**ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា**

**០១:២៩:០០**

**៤៦ទំព័រ**

ដានី ៈ លោកពូដឹបូងខ្ញុំ ចង់ស្គាល់ឈ្មោះលោកពូ លោកពូឈ្មោះពេញអីដែរ?

សំអុន ៈ ឈ្មោះពេញខ្ញុំឈ្មោះ យ៉ែម សំអុន ។

ដានី ៈ យ៉ែម សំអុនពូ?

សំអុន ៈ បាទ ។

ដានី ៈ អាយុប៉ុន្មានហើយពូសព្វថ្ងៃ?

សំអុន ៈ អាឡូវហ្នឹង ប្រហែលជា ៦០ ហើយ ៦០គត់ ខ្ញុំកើតឆ្នាំ១៩៥០ ។

ដានី ៈ ១៩៥០?

សំអុន ៈ បាទ ។

ដានី ៈ ពូអ្នកស្រុកកំនើតកើតជា នៅភូមិឃុំហ្នឹងបណ្តោយ?

សំអុន ៈ មិនមែនទេ ខ្ញុំនៅស្រុកត្រាំកក់ ភូមិកល់គម ឃុំញ៉ែងញ៉ង ។

ដានី ៈ ភូមិក្បាល?

សំអុន ៈ កល់គម ។

ដានី ៈ កល់គម?

សំអុន ៈ បាទ ។

ដានី ៈ ឃុំញ៉ែងញ៉ង?

សំអុន ៈ បាទ! ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានី ៈ  អញ្ជើងសព្វថ្ងៃនេះពូរស់នៅភូមិឃុំស្រុកអីដែរ?

សំអុន ៈភូមិពងទឹក ឃុំស្រែចែង ។

ដានី ៈ  ស្រុកជុំគីរី?

សំអុន ៈបាទ!ស្រុកជុំគីរី ខេត្តកំពត ។

ដានី ៈ  គ្រួសារលោកពូគាត់ឈ្មោះអីដែរ?

សំអុន ៈឈ្មោះ ខាត់ សូវ ។

ដានី ៈ  ខាត់ សូវ?

សំអុន ៈបាទ ។

ដានី ៈ  គាត់អាយុប៉ុន្មានដែរ?

សំអុន ៈគាត់អាយុចូល៥៦ហើយឆ្នាំនេះ ។

ដានី ៈ  ពូមានកូនទាំងអស់ប៉ុន្មាននាក់ដែរ?

សំអុន ៈកូនទាំងអស់៥នាក់ ទាំងអស់ ។

ដានី ៈ  ៥នាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សំអុន ៈបាទ!ស្រី២ប្រុស៣ ។

ដានី ៈ  ស្រី២ប្រុស៣?

សំអុន ៈកូនស្រីមួយកើតជម្ងឺប៉ូលយោ ។

ដានី ៈ  សព្វថ្ងៃពូប្រកបរបររកស៊ីធ្វើអីដែរ?

សំអុន ៈខ្ញុំនៅលក់ដូរបន្តិចបន្តួចក្នុងផ្ទះហ្នឹង ។

ដានី ៈ  លក់ដូរអ្ហូរ? អត់មានធ្វើអីទៀតទេ?

សំអុន ៈបាទ!អត់ទេ ។

ដានី ៈ  ពូឪពុកពូគាត់ឈ្មោះអីទៅ?

សំអុន ៈឪពុកខ្ញុំឈ្មោះ យ៉ែម ញ៉ែត ។

ដានី ៈ  យ៉ែម ញ៉ែត?

សំអុន ៈបាទ ។

ដានី ៈ  សព្វថ្ងៃគាត់នៅទេ?

សំអុន ៈគាត់ស្លាប់អស់ហើយ ។

ដានី ៈ  ស្លាប់តាំងពីអង្កាល?

សំអុន ៖ ស្លាប់ គាត់ស្លាប់យូរហើយ តាំងពីជំនាន់ ឆ្នាំមួយពាន់ប៉ុន្មានទេ ខ្ញុំកើតអត់ទាន់គាត់ផង ។

ដានី ៖ បាទ! ចុះម្ដាយ?

សំអុន ៖ ម្ដាយក៏ស្លាប់ដែរ ។

ដានី ៖ ម្ដាយ គាត់ឈ្មោះអីដែរ?

សំអុន ៖ ឈ្មោះ នូ ខាត់ ។

ដានី ៖ នូ ខាត់?

សំអុន ៖ បាទ ។

ដានី ៖ ពូបងប្អូនបង្កើតទាំងអស់មានប៉ុន្មាននាក់?

សំអុន ៖ បងប្អូនខ្ញុំបង្កើត៧នាក់ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សំអុន ៖ ស្រីតែ១ទេ ប្រុស៦ ។

ដានី ៖ ប្រុស៦?

សំអុន ៖ បាទ ។

ដានី ៖ ពូកូនទីប៉ុន្មានដែរ?

សំអុន ៖ ខ្ញុំកូនទី៤

ដានី ៖ កូនទី៤?

សំអុន ៖ បាទ ។

ដានី ៖ កាលពីក្មេងៗពូរៀនសូត្រអីនៅសាលាណា រៀនដល់ណាដែរ?

សំអុន ៖ ខ្ញុំពីមុននៅក្នុងវត្ត រៀនសាលាវត្ត រួចហើយខ្ញុំឡើងដល់សាលាផ្សារជំនាន់មុននោះណា ឡើងដល់ថ្នាក់ទី៧ហើយ ថ្នាក់ទី៧ជំនាន់មុន គេហៅសិបប៉ាយ័រហ្នឹង ។

ដានី ៖ នៅសាលាណាទៅ?

សំអុន ៖ នៅសាលាត្រាំកក់ ផ្សារត្រាំកក់ហ្នឹងហ្នង ។

ដានី ៖ ដល់ពេលពូរៀនដល់ថ្នាក់ទី៧ហើយយ៉ាងម៉េចទៀត?

សំអុន ៖ ខ្ញុំក៏ឈប់ ។

ដានី ៖ ឈប់មកយើងមកធ្វើអីវិញ?

សំអុន ៖ ឈប់មកខ្ញុំមកបួសវិញ ចូលបួស ។

ដានី ៖ បួសនៅវត្តណាដែរ?

សំអុន ៖ បួសនៅវត្តកោះកែ្អក ហៅថាវត្តកខានារាម ។

ដានី ៖ នៅណាវត្តហ្នុង?

សំអុន ៖ បាទ!វត្តកោះកែ្អក នៅខាងជើងកល់គម ត្រាំកក់ ខាងជើងត្រាំកក់តិច ។

ដានី ៖ ឆ្នាំណាដែលពូចូលបួស?

សំអុន ៖ ឆ្នាំ១៩៦៤ ។

ដានី ៖ បន្ទាប់ពីឈប់រៀនភ្លាមយើងទៅ?

សំអុន ៖ ទៅបួស ។

ដានី ៖ ពូបួសបានប៉ុន្មានវស្សារដែរ?

សំអុន ៖ ខ្ញុំដល់ឆ្នាំ៧០ សង្គ្រាមហើយ ខ្ញុំសឹក ឆ្នាំ១៩៧០ ខ្ញុំសឹក សឹកចូលធ្វើការឲ្យគេទៀត ។

ដានី ៖ ដល់ពេលសឹកឆ្នាំ៧០ហ្នឹងលោកពូចូលធ្វើការងារអីទៅ?

សំអុន ៖ គេបបួលចូលគេឲ្យ ធ្វើស្មៀនឃុំគេ ស្មៀនឃុំជំនាន់ប្រជាជាតិហ្នឹង ។

ដានី ៖ ស្មៀនឃុំ?

សំអុន ៖ ស្រែចែង ។

ដានី ៖ កាលហ្នុងគណៈឃុំគាត់ឈ្មោះអីទៅ?

សំអុន ៖ កាលហ្នឹងឈ្មោះ អួរ..ភ្លេចអស់ហើយ..ឈ្មោះតាសូរ ។

ដារ៉ា ៖ មកធ្វើស្មៀនឃុំនៅស្រែចែងហ្នឹងនេះ?

សំអុន ៖ បានស្រែចែង ស្រុកខាងប្រពន្ធខ្ញុំនេះ ។

ដានី ៖ ម៉េចបានលោកពូរៀបការក្នុងឆ្នាំណាអញ្ចឹង?

សំអុន ៖ ខ្ញុំរៀបការឆ្នាំ៧០ ។

ដានី ៖ ឆ្នាំ៧០?

សំអុន ៖ បាទ!សឹកមកហើយបានប៉ុន្មានខែ ក៏ការទៅ មិនទាន់ដុះសក់ស្រួលផង ។

ដានី ៖ ដល់ពេលលោកពូការហើយយ៉ាងម៉េច លោកពូចូលស្មៀនឃុំហ្នឹងតាមរយៈយ៉ាងម៉េចដែរ?

សំអុន ៖ ហ្នឹងតាមរយៈហ្នឹងអីញ្ចេក កាលនៅលោកគេទៅរៀនបាលី អីនៅស្រុកគេហ្នឹងណា ហើយមនុស្សដែលនៅនេះគេស្គាល់ខ្ញុំ ឃើញខ្ញុំមកនៅនេះ ។ គេស្គាល់ខ្ញុំអញ្ចឹងគេធ្វើការមួយនេះហ្នឹងក៏គេបបួលខ្ញុំទៅធ្វើការមួយគេដែលទៅ ហើយខ្ញុំក៏ទៅធ្វើការហ្នឹងគេដែលទៅ ។គេអ្នកស្រុកហ្នឹងគេមានទំនាក់ទំនងខាងខ្មែរក្រហម ។ មុនអីនោះណា គេដឹង គេធ្វើជាប្រធានឃុំនៅហ្នឹង មេឃុំ

កាលហ្នឹងគេហៅថាប្រធានឃុំអញ្ចឹងហើយ គេក៏បបួលខ្ញុំឲ្យចូលធ្វើនឹងគេទៅ ។ ធ្វើនឹងគេ គេឲ្យធើស្មៀនហ្នឹងឲ្យជួយសរសេរជួយអីគេតិចតួចហ្នឹងប៉ុណ្ណឹងទេ ។

ដានី ៖ គាសួរអ្នកហៅ?

សំអុន ៖ ឈ្មោះគាសួរឈ្មោះសេម...ឈ្មោះសេម មួយទៀត សួរមួយ ឈ្មោះសេមមួយ ។

ដានី ៖ ពូធ្វើស្មៀនឃុំហ្នឹង ធ្វើបានរយៈពេលប៉ុន្មានដែរ?

សំអុន ៖ ខ្ញុំធ្វើបានខ្លីទេ ព្រោះខ្ញុំធ្វើកាលហ្នឹង ធ្វើបាន១ឆ្នាំដាងខ្ញុំក៏ឈប់ទៅ បានខ្ញុំឈប់ ព្រោះកាលហ្នឹងខ្ញុំគ្រុន គ្រុនមកនៅនឹងផ្ទះ នៅផ្ទះយូរពេកទៅ ខ្ញុំខ្មាស់គេ ខ្ញុំឈប់ សុំគេឈប់ទៅ ឈប់ធ្វើក៏ផ្អាកនៅផ្ទះជាមួយប្រពន្ធខ្ញុំទៅ ។

ដានី ៖ ចុះពូកាលយើងធ្វើស្មៀនឃុំ ឃុំជំនាន់ហ្នុងការងារគេធ្វើអី?

សំអុន ៖ ការងារអីដូចគ្មានពិបាកទេ ព្រោះខ្ញុំខបមាគេត្រូវការសំបុត្រស្នាមអីដើរទៅណាមកណាគេឲ្យខ្ញុំជួយសរសេរឲ្យគេទៅណា ហើយខ្ញុំក៏សាញ៉េជំនួសគេហ្នឹងទៅយើងដាក់“ជ១” អញ្ចឹងទៅយើងដាក់ជំនួសអញ្ចឹងទៅ យើងធ្វើឲ្យគេទៅ ហើយគ្មានអីទាក់ទិនទេ ។ គេដើរទៅណាទៅណាឆ្លងស្រុកមួយទៅស្រុកមួយអីហ្នឹង អាហ្នឹងដើរបានម៉ាសេរីភាព គ្រប់គ្រាន់ ស្រុកមួយ ស្រុកមួយអី ហើយទៅតាមឃុំអីកោះប្រជុំក៏ត្រូវការរទេះត្រូវការអីដឹកជញ្ជូនគ្រាប់ ដឹកជញ្ជូនរំសេវអីគឺយើងមានអ្នករត់ការយើងអត្តុយតែសរសេរទេ ។

ដានី ៖ តែនៅជំនាន់ហ្នុង ដូចថានៅក្នុងស្រុកភូមិយើងនៅស្រែចែងហ្នឹង កាលហ្នឹងខាងខ្មែរក្រហមគេគ្រប់គ្រងឬក៏ខាងលន់ នល់?

សំអុន ៖ កាល

ហ្នឹងខ្មែរក្រហមគ្រប់គ្រងហើយ ព្រោះដីនេះសុទ្ធជាតំបន់រំដោះហើយបាទ! តំបន់រំដោះ គឺចាប់ផ្ដាប់គឺចូលមកក្ដិប រំដោះបានពួក លន់ នល់ ពួកអីបាត់អស់ហើយ ទៅឆ្ងាយៗអស់ ហើយ ។

ដានី ៖ អញ្ចឹងប្រជាជនយើងនៅនេះដូចថា កាលហ្នុងយើងនៅមួយខ្មែរក្រហមដូចថា?

សំអុន ៖ បាទ!គឺនៅមួយគ្នា ក៏ប៉ុន្តែការរស់នៅគឺដូចធម្មតា អវត្តមានគារឿងលន់ នល់ អវត្តមានគារឿងនោះទេ ។ តែការរស់នៅរបៀបរបប គឺនៅបាយទឹកអី ហូបចុកតាមឯកជនធម្មតាទេ អាហ្នឹងកាលខ្ញុំនៅ កាលខ្ញុំនៅធ្វើការ ។

ដានី ៖ ចុះពូអញ្ចឹង ពូធ្វើបានប៉ុន្មានឆ្នាំពូឈឺទៅ ហើយក៏ពូឈប់មកនៅមួយប្រពន្ធ?

សំអុន ៖ បាទ!មកនៅមួយប្រពន្ធវិញ ។

ដានី ៖ ហើយយ៉ាងម៉េចទៀតទៅពូ?

សំអុន ៖ ហើយ ដល់ឆ្នាំ១៩៧៣ កាលហ្នឹងកូនខ្ញុំនៅក្នុងពោះហើយគ្រប់ខែហើយ ជំនាន់ហ្នុងគឺ ប៉េ៥២ ទម្លាក់ ខ្ញុំក៏ស្តាប់សភាពការណ៍ដូចមិនសូវស្រួល ព្រោះកាលហ្នុងមានឈ្មោះ ឈ្មោះដែលគេហៅថាសត្តិសម្ព័ន្ធ ដូច្នេះខ្ញុំក៏ផ្អាកការងារធ្វើហាក់ដូចជាខ្ញុំស្ពឹកស្រពន់ចំពោះការងារហ្នឹង ខ្ញុំក៏សូមប្រធានភូមិហ្នឹងទៅទ័ពវិញទៅ ។

ដានី ៖ យ៉ាងម៉េចទៅពូ ពូអាចរៀបរាប់កន្លែងហ្នឹង ដូចថាពេលពូសុំចូលទ័ពហ្នឹង សុំចូលទ័ពទៅកន្លែងណា ធ្វើអីខ្លះទៅ?

សំអុន ៖ បាទ!បានធ្វើទ័ពហ្នឹងខ្ញុំក៏អនុញ្ញាតឲ្យទៅ ទៅហ្នឹងទៅទាំងប្រពន្ធគ្រប់ខែទៀត ខ្ញុំទៅបានមួយអាទិត្យខ្ញុំដឹងថាប្រពន្ធខ្ញុំសម្រាលកូនទីមួយហើយ កូនដំបូងបំផុតឆ្នាំ៧៣ហ្នឹង កូនស្រី ហើយរួចពីហ្នឹងទៅខ្ញុំទៅទ័ព ។ គេអត់ឲ្យទៅទ័ពទៀតគេមិនឲ្យខ្ញុំធ្វើទ័ពទេ គេឲ្យខ្ញុំទៅលក់ដូរគេ នៅឯទាន់ហន់ ទាន់ហន់ ស្មៀនឃុំយើងនៅស្រុកយួនហ្នឹង កំពង់អួន ទៅលក់ដូរឥវ៉ាន់ហ្នឹង លក់ដូរឥវ៉ាន់ជំនួញឥវ៉ាន់ពីលើថាអីញ្ចេក ឧបមាថាយើងយកជាដូង ជាព្រីង ជាចំនីចំនុកអី ជ្រូកអីអីហ្នឹងយើងយកទៅដូរជាក្រណាត់ ខោអាវអី មកចែកជូនប្រជាជនយើងនៅក្នុងមូលដ្ឋាននេះ ។ ហៅថាមូលដ្ឋានពីដើម គេដោះដូរខាងហ្នឹង កុំឲ្យមានការខ្វះខាតអីមានតាំងពីប៊ីចេង គឺយកពីហ្នឹងមកវិញមកផ្តល់ឲ្យប្រជាជនយើងស៊ីចុកគ្រប់គ្រាន់នៅខាងនេះ ។

ដានី ៖ អាហ្នឹងលក់ដូរយ៉ាងម៉េច?

សំអុន ៖ លក់ដូរឧបមាយើងទិញឥវ៉ាន់ពីស្រុកយួនហ្នុងយើងយកឥវ៉ាន់យើងពីនេះទៅ ទៅដូរនៅស្រុកយួនដូរស្រុកយួនមានទាំងប៊ីចេង មានទាំងចានឆ្នាំងគ្រប់មុខទាំង អស់សុទ្ធអញ្ចឹងៗគ្រប់ទាំងអស់អញ្ចឹង ហើយខាងភូមិយើងពីនេះទៅជនបទអញ្ចឹងអត់ មានបង្កើតទីផ្សារធំបានទេ យកទៅហ្នឹងទៅតិចទេ ។ ឥវ៉ែឥវ៉ាន់ទៅហ្នុងទុកកន្លែងខ្ញុំហ្នឹង ដឹកទាំងអាទេះៗជូនបងប្អូនយើងលក់ដូរនេះទៅ ។ កាលហ្នុងចាយលុយទេ លុយអារូបគោ រូបគោរបស់លន់ នល់ដែរហ្នឹងនៅចាយលុយ ។

ដានី ៖ អញ្ចឹងនៅខាងរំដោះហ្នឹងគេចាយលុយ លន់ នល់ដែរ?

សំអុន ៖ បាទ!ចាយលុយ លន់ នល់ កាលហ្នឹង បើមិនផ្លាស់ប្តូរគ្នាអញ្ចឹងអត់ទៅរួចទេ ដោះដូរជាមួយយួនអត់កើត ។

ដានី ៖ កាលហ្នឹងពូលក់ដូរអញ្ចឹងពូនៅក្នុងអង្គភាពអីទៅ?

សំអុន ៖ អង្គភាពពាណិជ្ជហ្នឹង គេហៅពាណិជ្ជហ្នឹង វាសាខាពាណិជ្ជតំបន់គេ តំបន់គេហៅខេត្ត ជាសាខារបស់គេដែលប្រចាំការនៅច្រកហ្នឹងម្នងប្រញាប់ជញ្ជូនឥវ៉ាន់មកឲ្យខាងខេត្តគេនេះ ។

ដានី ៖ កាលហ្នឹងគេហៅយើងពួកពាណិជ្ជ ពាណិជ្ជកម្ម?

សំអុន ៖ បាទ!ពួកពាណិជ្ជ ពាណិជ្ជកម្ម ។

ដានី ៖ ពាណិជ្ជកម្ម?

សំអុន ៖ បាទ!ពាណិជ្ជកម្ម ។

ដានី ៖ ពាណិជ្ជកម្មតំបន់ កាលហ្នុងតំបន់នៅណាដែរ?

សំអុន ៖ តំបន់ តំបន់ហ្នឹងកាលហ្នុងគេហៅតំបន់កំពត គេហៅលេខ លេខពីដើមគេហៅ៣៥ ។

ដានី ៖ តំបន់៣៥?

សំអុន ៖ បាទ ។

ដានី ៖ ហឺ!ដល់ពេលពូនៅសាខាគេឲ្យនៅសាខា សាខាអីគេ?

សំអុន ៖ សាខាពាណិជ្ជ នៅទាន់ហន់ ហ្នឹងម្ទង ។

ដានី ៖ សាខាពាណិជ្ជនៅទាន់ហន់?

សំអុន ៖ បា.ទ!ស្ពានធំ នៅវែងៗហ្នឹងគេហៅសាខាស្ពានធំ ព្រោះទាន់ហន់សុទ្ធតែយួនធៀវគីនៅ កាលហ្នឹងធៀវគី នៅទេអត់ទាន់អស់ទេ ធៀវគីរនៅ ខ្ញុំនៅទល់មុខគ្នាហ្នឹងទល់គ្នា ។

ដានី ៖ ចុះពូដូចថាពូដូចថាពួកខាងរំដោះអញ្ជឹង ដូចខាងធៀវគី ធៀវគីគេត្រូវជាមួយ លន់ នល់ ចុះពូទៅរកស៊ីយ៉ាងម៉េចទៅ?

សំអុន ៖ តាមរយៈឈ្មួញ ឈ្មួញអ្នករត់ការយកយើង ដូច្នេះឈ្មួញវាមិនអាចនេះទេ ឈ្មួញខាងណាក៏វាត្រូវដែរ អាលើក៏វាត្រូវ អាក្រោមក៏វាត្រូវ ឲ្យតាបានផលវា វាយកពីយើងទៅផង ទៅដាក់ឯណោះទៅ វាយកពីនោះមកផង មកដាក់ឯនេះមក តាមរយៈឈ្មួញទេ យើងមិនអាចទាក់ទងទល់មុខគ្នាបានទេ ព្រោះអាសាវវៃគ្នាដែរពួកហ្នឹង ។

ដានី ៖ ចុះលន់ នល់ អីគេអត់ដឹងទេ?

សំអុន ៖ អត់ដឹងទេ..លន់ នល់ អត់មានបៀតទេកន្លែងនេះនោះ លន់ នល់ មកនៅម្តុំដើងតាម្តុំយើងកំពតនេះតើ គេវ៉ៃរួចក្លួលហើយពួកទ័ពខាងទ័ព ។

ដានី ៖ ទូកមាសអីអត់មានទេ?

សំអុន ៖ ទូកមាស មាន អាហ្នឹងនៅមួយៗ នៅមានទូកមាសទៅកំពតកាលហ្នឹង កាលខ្ញុំនៅហ្នឹង នៅទូកមាស ហឺ!កំពតបាទ!មិនទាន់ដាច់មិត្តទេ ។

ដានី ៖ អញ្ជឹងពូដែលខាងពាណិជ្ជយើងយករបស់ទៅដូរយកឥវ៉ាន់ពីស្រុកយួនមកវិញ យើងយកមកផ្គត់ផ្គង់ឲ្យប្រជាជនឬផ្គត់ផ្គង់ឲ្យកងទ័ព?

សំអុន ៖ ផ្គត់ផ្គង់ឲ្យប្រជាជន ព្រោះរបស់សុទ្ធជារបស់ប្រជាជនទាំងអស់ ខ្ញុំអត់មានខាងការភ្លើង ខាងគ្រាប់រំសេវអីទេ គឺមានតាំងពីការណាត់ ការណាត់ហ្នឹងការណាត់ប្រណិតទៀតណាស់ ក្រណាត់ខ្មៅអីអី ។ ក្រណាត់ផ្ការអីតិចតួចហ្នឹងហើយចាន់ឆ្នាំង សុទ្ធតែសម្រាប់ប្រជាជនទាំងអស់ហ្នឹង អំបិល ប៊ីចេង អីអី យកមកខ្ញុំមិនដឹងថាចែកចាយទៅណា ប៊ីចេងអី មិនដឹងទេ ចានឆ្នាំងអី គ្រាន់តែដឹងថាគ្មានអាវុធយុទ្ធភ័ណ្ឌសម្រាប់យោធាទេ ។ កន្លែងខ្ញុំសម្រាប់ប្រជាជនសុទ្ធសាធ ដែលរបស់របរទាំងអស់ ប្រេងក្រឡា ប្រេងអីហ្នឹង ។

ដានី ៖ ដឹកតាមរទេះ?

សំអុន ៖ បាទ!ដឹកតាមរទេះតាមភូមិៗគេទៅមួយៗ តាមភូមិអញ្ចឹង ភូមិ"ក" ភូមិ"ខ" អញ្ចឹងទៅអ្នកណាគេចង់យកឥវ៉ាន់មកឲ្យខាងភូមិគេ គេយករទេះមកដឹកមក ហើយគេឲ្យលុយមកខ្ញុំមក ហើយខ្ញុំយកលុយទៅជូរគេទៅ ទៅទិញឥវ៉ែឥវ៉ាន់ប្រជាជនគេទៅដូរជាមួយយួនទៀតទៅ បានមួយអាធៀវគីទៀតទៅ ។

ដានី ៖ គ្នាពូប៉ុន្មាននាក់ទៅ?

សំអុន ៖ ខ្ញុំ គ្នាខ្ញុំវាម៉ាកងការពារហ្នឹងម៉ាក្រុម ហ៊ីពួកខ្ញុំម៉ាខ្ទង់រផ្ទង់ហ្នឹងតាបីនាក់ទេ ក្នុងរផ្ទង់លក់ដូរ កន្លែងលក់ដូរហ្នុង ។

ដានី ៖ មានអ្នកការពារដែរ?

សំអុន ៖ បាទ!មានកម្លាំងការពារ ។

ដានី ៖ ការពារជាកងទ័ព?

សំអុន ៖ កងទ័ពម៉ាក្រុម មនុស្សដូចកងទ័ពអញ្ចឹងណាវាតាម៉ាក្រុមហ្នឹងណា ។

ដានី ៖ មកពីណាកងទ័ពហ្នឹង?

សំអុន ៖ គេ មិនដឹងថាគេឲ្យមកពីណា ឲ្យមកតែសម្រាប់តែការពារកន្លែងខ្ញុំនឹងម្នង គេរស់ដោយគេទៅខ្ញុំរស់ដោយខ្ញុំទៅ ។

ដានី ៖ ចុះគ្នាពូតែបីនាក់ទេ?

សំអុន ៖ បីនាក់ទេ ។

ដានី ៖ ឈ្មោះអីខ្លះទៅពូមានដឹងទេ?

សំអុន ៖ ខ្ញុំ ឈ្មោះបងសាយមួយប្រធានខ្ញុំ ខ្ញុំអនុទេ ។

ដានី ៖ ឈ្មោះសាយ?

សំអុន ៖ បាទ ។

ដានី ៖ សាយ ពូ ហើយពីណាម្នាក់ទៀត?

សំអុន ៖ ហីម្នាក់ទៀតឈ្មោះដួង ពិន ដួង ហ្នឹងគេជាប្រធានក្រុមសម្រាប់ការពារហ្នឹង ។

ដានី ៖ ដួង ប្រធានក្រុមការពារ?

សំអុន ៖ ប្រធានក្រុមការពារទេ ។

ដានី ៖ ការពារម៉ាក្រុមហ្នឹងមានកាំភ្លើងមានអីគ្រប់ដៃ?

សំអុន ៖ កាំភ្លើងគេមាន ។

ដានី ៖ កាំភ្លើងអីខ្លះ?

សំអុន ៖ កាំភ្លើងហ្នឹង កាំភ្លើងអាកា ហីសេកាសេហ្នឹង ។

ដានី ៖ ជាកងឈ្លបទេ មិនមែនជាកង?

សំអុន ៖ មិនមែនជាកងឈ្លបទេ អាចថាអញ្ចឹងចោះ ជាកងការពារហ្នឹងណា សម្រាប់ការពារកន្លែងហ្នឹងមួយ ។

ដានី ៖ បើចឹងប៉ុន្តែក្រុមរបស់ពូជាសាខារបស់តំបន់ យើងទាក់ទងជាមួយតំបន់អីយ៉ាងម៉េច?

សំអុន ៖ ខ្ញុំអត់ដែលទៅទាក់ទងផង ប្រធានគេទៅ គេឡើងទៅប្រជុំគេឡើងទៅហើយ ខ្ញុំចេញម៉េចរួចបើកន្លែងចឹង ហីប្រធានអត់ចេះទេ គាត់មិនចេះអក្សរទេ ហើយអត់ចេះគិតលេខទេ អក្សរអីហ្នឹងអត់ចេះទេគ្រាន់តែធ្វើមេ ។

ដានី ៖ គាត់ធ្វើមេ?

សំអុន ៖ បាទ!ធ្វើមេខ្ញុំអនុហ្នឹងអត់មានទេ ដូចស្រីអញ្ចឹងនៅតាកន្លែងគត់ កន្លែងគត់លក់ដូរអីហ្នឹង មានតែគេមកជួយហ្នឹង ពួកអាក្រុមអីក្រុមដួង ហ្នឹងពីរបីនាក់មកនៅជួយលក់គោងនេះ គោងនោះលក់ទៅ បើប្រធាននោះធ្វើមិនកើតទេ ។

ដានី ៖ ចុះពាណិជ្ជកម្មតំបន់ពីណាគេទៅកាលហ្នឹង?

សំអុន ៖ អត់ស្គាល់ ។

ដានី ៖ អត់ដែលស្គាល់?

សំអុន ៖ បាទ!ខ្ញុំអត់ស្គាល់ឈ្មោះអស់ទេ មិនដឹងឈ្មោះអីខ្លះអីខ្លះទេ ។

ដានី ៖ អត់ដែលបានជួបគាត់ទេ?

សំអុន ៖ អត់ដែលជួបទេ ។

ដានី ៖ គណៈតំបន់?

សំអុន ៖ គណៈតំបន់ស្គាល់ តាចាប ។

ដានី ៖ កងចាប?

សំអុន ៖ បាទ!កងចាប អ្ហឹ..បែប កងចាប ហ្នឹងហើយខ្ញុំមិនស្គាល់ច្បាស់ទេ ខ្ញុំមិនសូវស្គាល់ទេ ។

ដានី ៖ ដែលឃើញគាត់ទេ?

សំអុន ៖ ដែលឃើញម្តង ។

ដានី ៖ ឃើញគាត់ពេលណាហ្នឹង?

សំអុន ៖ ពេលដែលហៅទៅប្រជុំ ហៅប្រជុំឃើញគាត់នេះចឹងដៃហ្នុងដូចដៃភ្លុំ ដើរក្រោយខ្ញុំ ខ្ញុំដើរមុខ ពួកហ្នុងក្មេងដើរគ្នា វានិយាយគាពីរឿងនំអន្សម ហ៊ីខ្ញុំថាអត់ហែវទេនំអន្សម អត់ហែវអត់អីទេខែនេះហើយ រួចហើយបានថាមែនបាច់ហែវទេ ដល់ពេលផាកទៅបានដឹងថាតាចាប ស្គាល់ម្តងហ្នឹង ។

ដារ៉ា ៖ រូបរាងគាត់ម៉េចពូ?

សំអុន ៖ គាត់ធាត់ ហ៊ី ស ។

ដានី ៖ ចុះពូស្គាល់គាត់ម្តង ថីបានស្គាល់គាត់ថាឈ្មោះតាចាប?

សំអុន ៖ អូរ!អ្នកណាក៏គេហៅដែល គេហៅគ្រប់គ្នាយើងក៏ស្គាល់តាម ហៅលឺសូរដូចយក្សចឹង ។

ដានី ៖ ឆ្នាំណាដែលពូឃើញគាត់?

សំអុន ៖ ឃើញគាត់នៅឆ្នាំ៧៨ហើយ ។

ដានី ៖ ឆ្នាំ៧៨?

សំអុន ៖ បាទ ។

ដានី ៖ ឃើញនៅណា?

សំអុន ៖ ឃើញនៅហ្នឹង នៅវត្តគយ វត្តគយយើង ហៅវត្តគយ វត្តគយ គេមកប្រជុំកន្លែងហ្នឹង ។

ដានី ៖ វត្តគយនៅណា នៅក្នុងស្រុកជុំ?

សំអុន ៖ មែនជុំគីរី កោះស្លា ។

ដានី ៖ កោះស្លា?

សំអុន ៖ បាទ!អាឡូវហ្នឹង មុននៅណាអីណីទេ ខ្ញុំវាមិនសូវច្បាស់ ព្រោះនៅតែនៅនោះ ខ្ញុំមិនសូវដែរដើរទៅណាណីនឹងគេទេ នៅតាកន្លែងហ្នឹង នៅណានៅហ្នឹងហើយខ្ញុំ ។

ដានី ៖ ក្រៅពីហ្នឹងមានដែលឃើញគាត់នៅណាទៀតទេ?

សំអុន ៖ អត់ដែរ..ព្រោះខ្ញុំអត់ដែលដើរសោះ ។

ដានី ៖ ចឹងតំបន់៣៥ ហ្នឹងគណៈតំបន់គាត់មានតាំងពីឆ្នាំ៧០ប៉ុន្មានមក?

សំអុន ៖ លីសួរ គាកងចាប ហ្នឹងតាំងពី៧០ម៉ោ ។

ដានី ៖ តាំងពី៧០?

សំអុន ៖ តែខ្ញុំមិនលឺសួរកងចាប ទើបតែលឺលោកគ្រូនិយាយមិញទេ ខ្ញុំស្គាល់តែតាចាប តាចាបហ្នឹង ។

ដានី ៖ តាចាប តាចាបទេ?

សំអុន ៖ បាទ!តាចាប តាចាប គាត់គណៈតំបន់តាំងពី៧០ម៉ោនោះ ។

ដានី ៖ ចុះគណៈតំបន់ដូចថាមានគ្នា ពីរ បីនាក់អីចឹងមែន?

សំអុន ៖ បាទ!មិនដឹងប៉ុន្មាននាក់ទេ អត់ដឹងមិនសាខាប៉ុន្មាន ពិនតែឈ្មោះច្បាស់ជាងគេ គឺតា ចាបហ្នឹង ហើយច្បាស់ណាស់ មិនដឹងថាណាគេតំបន់ខ្លះ ណាមែនតំបន់ខ្លះទេ ខ្ញុំអត់ចងចាំ ។

ដានី ៖ ចឹងពូនៅពាណិជ្ជកម្ម កន្លែងទាន់ហាន់ ហ្នឹងនៅពី៧៣ ដល់ឆ្នាំណាដែរ?

សំអុន ៖ បាទ!ពី៧៣រហូតដល់៧៥ ៧៥ហ្នឹងគឺនៃក្នុងភូមិយើងហ្នឹងកាលហ្នឹងមានវៀតណាមវានៅនេះ ណា ដល់ខ្មែរក្រហមនិងវៀតណាមវាទន្ទិចគ្នាសរឿងអីទេ ។ ខ្មែរក្រហមវៃទៅរុញវៀតណាម ទៅនៅនឹងនោះទៅធ្លាក់ទៅនៅហ្នឹងខ្ទប់ខ្ញុំកន្លែងហ្នឹងកន្លែងទាន់ហាន់ហ្នឹង ។ ខ្ញុំកុំបានឈ្លបខាង ស្រុកកំពង់ត្រាចនាំចេញ កុំអីវៀតណាមខាងលើដែលចុះពីនេះទៅលេងខ្ញុំបាត់ហើយ ។ បានខ្ញុំ គេចទៅរួចទៅក្នុងកំពង់ត្រាចទៅ ចេញពីកំពង់ត្រាចទៅបានដកមកនៅដងទង់ ។ គេវៃ បែកទូក មាសហើយ ស្ពឺមាស ក្បាលរមាស បែកក្បាលរមាស បានបែកក្បាលរមាស ហ្នឹងហើយ ខ្ញុំនៅខាងកើតហ្នឹង ។ នៅកំពង់នន់ហើយហ្នឹងទៅក៏គេរៀបចំឲ្យខ្ញុំចូលទ័ពទៅខ្ញុំលែង អានោះឥវ៉ៃ ឥវ៉ាន់អីចោលខ្ទេចខ្ទីអស់ហើយ ។ ខ្ញុំចូលទ័ពចូលទ័ពបានប្រហែលជាមួយខែនៅកំពតហ្នឹង ព័ទ្ធកំពតហ្នឹងហើយ ។ ព័ទ្ធអាខិញក្រុងកំពតហ្នឹងហើយ ដល់មិនបានវៃកំពតផង គេដកពួក ខ្ញុំទៅភ្នំពេញ ។ ទៅភ្នំពេញថ្ងៃទី១៤សម្រាកមួយថ្ងៃ ថ្ងៃទី១៥ សម្រាកទៀត ថ្ងៃទី១៦ ចូលសមរភូមិ ចូលសមរភូមិថ្ងៃ១៦ ហ្នឹងបាក់បស់លន់ នល់ វៃនៅអាខេញ កំបូល លន់ នល់ ដេញមកព្រៀតតាំងពីរថក្រោះផង កប៉ាល់ហោះផង ថ្មើរជើងផង ដេញបាក់បស់វា ដល់ស្អែកឡើងថ្ងៃទី១៧ មេសាបានបានវៃឈ្នះ បានឈ្នះ បានឈ្នះក៏រំដោះទៅ ។

ដានី ៖ ចុះពូមានប្រសាសន៍មិញថាខ្មែរក្រហមរុញវៀតណាមទៅខ្ទប់ពូវៀតណាមនៅយ៉ាងម៉េចពី ព្រោះ?

សំអុន ៖ វៀតណាមហ្នឹង វៀតណាមខាងជើង កាលហ្នឹងធៀវគី មិនទាន់រំដោះទេ វៀតណាមខាង ជើងហ្នឹងនៅកន្លែងរំដោះយើងនេះ មិនជាមានបញ្ហាអីខ្ញុំមិនដឹង គេបាញ់គ្នា គេបាញ់គ្នាវាមាន ខ្មែរក្រហមហីនឹងវៀតណាមហ្នឹងហើយដល់នេះក៏រុញវៀតណាមហ្នឹងចុះទៅស្រុកវាវិញយល់ ។

ដានី ៖ ឆ្នាំណាហ្នឹង?

សំអុន ៖ ឆ្នាំ៧៣ហើយ ចង់ចូលជិត៧៤ ហើយ៧០ប៉ុន្មានទេខ្ញុំភ្លេចហើយកាលហ្នឹងមានដីងអី ៧៤ ហើយព្រោះវាទៅម៉ារយៈទេបានរំដោះ ។

ដានី ៖ កាលហ្នុងអញ្ចឹងពូអត់ចាំឆ្នាំច្បាស់ទេ?

សំអុន ៖ មិនចាំឆ្នាំទេ ។

ដានី ៖ ៧៣ឬក៏៧៤កាលហ្នុង?

សំអុន ៖ កាលហ្នុង៧៤ ។

ដានី ៖ ចឹងដល់ពេលវៀតណាមរុញទៅយ៉ាងម៉េចពូ?

សំអុន ៖ ខ្ញុំទៅនៅហ្នឹង នៅហ្នឹងពិនខ្លាចគេដែរ ព្រោះទៅគេមានកំហឹងពីនេះដែរ យើងជាខ្មែរនៅនោះហ្នឹងគេខ្ទប់យើងជាប់ ព្រោះយើងនៅអីចេះ អានេះអាធីវ អានេះវៀតណាមចុះទៅ ហើយនេះខ្ញុំចេញប្រលោះនេះទៅ ខាងហ្នឹង ទ័ពស្រុកគេនៅហ្នឹងបានជួយយរំដោះចេញទាំងយប់ ។

ដានី ៖ ហីពូចូលកងទ័ពស្រុក?

សំអុន ៖ អត់ទេ ខ្ញុំចូលនៅតំបន់ហើយ ។

ដានី ៖ កងទ័ពតំបន់?

សំអុន ៖ បាទ!មកកងទ័ពតំបន់នៅកំពតហើយ ។

ដានី ៖ ចូលតំបន់ឆ្នាំ?

សំអុន ៖ ឆ្នាំ៧៥ ហើយខ្ញុំចូលហ្នឹង ។

ដានី ៖ ខែណា?

សំអុន ៖ ខែខ្ទង់ខែ៤ ។

ដានី ៖ ខែ៤បែកភ្នំពេញហើយ ។

សំអុន ៖ ខែ៤ អត់ទាន់បែកទេ ព្រោះខ្ញុំចូលខ្មី ចូលខ្មី ពិនខ្ញុំបើសិនចូលអានេះចូលមុន ខ្ញុំចូលប្រហែលខែ២ ។

ដានី ៖ ខែ២?

សំអុន ៖ បាទ!ខែ២ ខ្ញុំចូលទ័ពខែ២ ខ្ញុំនៅបង្ហើយអានេះជិត២ខែបានខ្ញុំឡើងទៅ ។

ដានី ៖ កាលហ្នឹងពូលទើបចូលទ័ពតំបន់៣៥ហ្នឹង?

សំអុន ៖ បាទ!ទ័ពតំបន់៣៥ ។

ដានី ៖ ពីណាគេប្រធានទ័ព?

សំអុន ៖ ប្រធានទ័ព ប្រធានវរៈខ្ញុំ សុខ សាន ។

ដានី ៖ តាសាន?

សំអុន ៖ បាទ ។

ដានី ៖ ចុះតាប៉ិត?

សំអុន ៖ អត់ដឹងទេ ។

ដានី ៖ អត់ស្គាល់សំ ប៉ិត ទេចឹង?

សំអុន ៖ បាទ! សំ ប៉ិត អត់ដែរ ខ្ញុំស្គាល់តែអត់ដែលមានឈ្មោះនៅក្នុងតំបន់នេះទេ ។

ដានី ៖ មិនដែលមានឈ្មោះហ្នឹងទេ?

សំអុន ៖ បាទ!មិនដែល ។

ដារ៉ា ៖ វរៈហ្នឹងពូសំដៅលើវរសេនាធំឬ?

សំអុន ៖ បាទ!វរសេនាតូច បានវរសេនាធំ ហូ យ៉ាន ស្គាល់ ស្គាល់មេៗ ។

ដានី ៖ ចឹងក្នុងតំបន់៣៥ហ្នឹងមានវរសេនាធំ?

សំអុន ៖ មានវរសេនាធំ ។

ដានី ៖ មានកងពលដែលអត់?

សំអុន ៖ នៅតំបន់ប្រហែលមានកងពល ពិនថាអត់មានដឹងថាណាជាកងពលផង ។

ដានី ៖ វរសេនាធំតាយ៉ាន?

សំអុន ៖ បាទ ។

ដានី ៖ វរសេនាតូច?

សំអុន ៖ វរសេនាតូចឈ្មោះ សាធ ។

ដានី ៖ ឈ្មោះ សាធ?

សំអុន ៖ បាទ ។

ដានី ៖ ពូនៅហ្នឹងបាន២ខែ?

សំអុន ៖ បាន២ខែ ។

ដានី ៖ ធ្វើអីខ្លះ?

សំអុន ៖ នៅហ្នឹងចូលតាសមរភូមិត្រៀមនៅហ្នឹង ធ្វើទៅផ្លាស់ប្តូរ ផ្លាស់ប្តូរតាមកន្លែង ទៅនៅស្រែអំបិល អត់មានលានក្បាលបានទេ ព្រោះថាបើលានក្បាលដ្ឋីបគឺបូមម៉ោហើយ កាលហ្នឹងផ្លោងបូម បាស់ត្រង់សេ បញ្ឈរឡើងលើទាំងអស់ ។

ដានី ៖ អត់ទម្លាក់?

សំអុន ៖ អត់ទេគ្រាប់ផ្លោង មានអាបូម បូមចឹង វាអត់មានអំបែងទេអាហ្នឹង វាចេញគាខ្យល់ម៉ោ ផ្ទុះគាំរំសេវម៉ោ ប៉ុន្តែយើងយកម្ចង់ ហើយឃើញច្បាស់ទៀតចុះបើស្រែអំបិល មានស្នោណាម៉ាទង អត់បានងើបក្បាលអត់បានទេ។

ដានី ៖ ពិនអាបូមហ្នឹងយើងស្លាប់ដែរអត់?

សំអុន ៖ ស្លាប់ អាហ្នឹងក៏ស្លាប់ដែរ ព្រោះអាកន្លែងណាដែលដីទន់វាមិនសូវដាក់អំបែងទេ។

ដារ៉ា ៖ ចង់ឲ្យពូជួយរៀបរាប់កន្លែង ពូថាមកភ្នំពេញថ្ងៃ១៥-១៦-១៧ហ្នឹង ឲ្យរៀងច្បាស់ជាងហ្នឹងបន្តិច?

សំអុន ៖ ថ្ងៃហ្នឹង ពេលចេញពីសមរភូមិគេដកទៅ ដកទ័ពទៅជួយវ៉ៃនៅភ្នំពេញ ទៅហ្នឹងទៅភ្នំពេញថ្ងៃ១៤ទៅថ្ងៃ១៣ថ្ងៃ១៣សម្រាកថ្ងៃ១៤សម្រាក អាហ្នឹងគេសុទ្ធតែកាប់គោឲ្យហូបហើយ មានសាច់គោសាច់អីហូប នៅតាមផ្លូវកាលហ្នឹងប្រជាជនយើងគាត់ឲ្យកន្សែងសូត្រឲ្យអីបោះ ឲ្យតាមឡាន តាមអីហ្នឹងជិះកឡានទៅ ធ្វើសមរភូមិទើប រំដោះហើយយើងអត់ភ័យភិតអីទេ ទៅហ្នឹងសប្បាយណាស់។ កាលហ្នឹងហ៊ីហារមែនទែនទ័ពគេ ហីប្រជាជនគាំទ្រខ្លាំងណាស់ ហើយទៅដល់ភ្នំពេញហ្នឹងសម្រាកដល់ថ្ងៃ១៥ថ្ងៃ១៦ខ្ញុំចូលសមរភូមិ ចូលសមរភូមិព្រឹកឡើងវ៉ៃគ្នាមួយសារដល់ហើយមុខសញ្ញាខ្ញុំបាក់របស់គេហើយ ដល់ថ្ងៃ១៧ ហ្នឹងអត់មានបាក់ទេ ក៏រំដោះទៅម៉ោង៩ជាងបានគេប្រកាសមកតាមវិទ្យុហ្នឹងទៅ រំដោះរួចខ្លួនទាំងអស់ទៅប៉ុណ្ណឹងទេអត់មានអីវែងឆ្ងាយទេ។

ដានី ៖ ពូពេលដែលគេបញ្ជូនពូទៅភ្នំពេញហ្នឹង ពូនៅកងតំបន់ដដែលឬក៏?

សំអុន ៖ កងតំបន់ដដែល ពិនទៅដល់នោះគេត្រូវដាក់ឈ្មោះផ្សេងហើយទៅជាភូមិភាគគេកងពល។

ដានី ៖ កងពលហើយ?

សំអុន ៖ បាទ!ជាកងពលហើយ កងពលខ្ញុំនៅកងពលទី៣ហើយ។

ដានី ៖ ក្នុងកងពលទី៣?

សំអុន ៖ បាទ។

ដានី ៖ របស់ភូមិភាគ?

សំអុន ៖ នីរតី។

ដានី ៖ ភូមិភាគនីរតី?

សំអុន ៖ បាទ។

ដានី ៖ ចុះពូអាចរៀបរាប់ថាពូចូលក្នុងកងពលទី៣ហ្នឹងពូនៅក្នុងកងធំកងតូចវរអីលេខប៉ុន្មាន?

សំអុន ៖ ហ្នឹងខ្ញុំនៅអត់មានលេខដង អត់ចាំលេខ ដឹងថានៅកងវរបងឈឿន បងឈឿនខ្មាក់ ។

ដានី ៖ ម៉ាឈឿន?

សំអុន ៖ បាទ!មិនដឹងឈ្មោះអីឈឿនទេ ។

ដានី ៖ គាត់នៅសំឡូត?

សំអុន ៖ បាទៗ ។

ដានី ៖ ហឹ អាហ្នឹងវរសេនាតូច?

សំអុន ៖ បាទៗ ។

ដានី ៖ វរសេនាតូចលេខប៉ុន្មានទៅហ្នឹង?

សំអុន ៖ វរសេនាតូចអត់ស្គាល់លេខទេ ។

ដានី ៖ វរសេនាធំ?

សំអុន ៖ វរសេនាធំនៅតាយ៉ានហ្នឹងដដែល ។

ដានី ៖ ចុះកងពល?

សំអុន ៖ កងពល តាមុត ។

ដានី ៖ តាមុត?

សំអុន ៖ បាទ!មាស មុត ។

ដានី ៖ មាស មុត កងពលទី៣?

សំអុន ៖ បាទៗកងពលទី៣ ។

ដានី ៖ ចឹងពូគ្រាន់តែចូលទៅដល់ពីរបីថ្ងៃហ្នឹងក៏បែកភ្នំពេញទៅ?

សំអុន ៖ បាទ!បានពីរបីថ្ងៃបែកភ្នំពេញទៅ ។

ដានី ៖ កាលហ្នុងកងពលរបស់ពូនៅម្តុំណាពេលយើងបែកហ្នឹង?

សំអុន ៖ នៅកំបូល ។

ដានី ៖ នៅកំបូល?

សំអុន ៖ ជាប់ថ្នល់អាទេះភ្លើងហ្នឹង គេហៅត្រពាំងក្តីម្តុំហ្នឹង ។

ដានី ៖ ចុះអីទៅដល់ពេលថ្ងៃបែក គឺថាដល់ពេលហ្នឹងពេលយើងបែកទៅ យើងចាប់ផ្តើមជ្រួលច្របល់មានប្រជាជនអីជម្លៀសចេញអី?

សំអុន ៖ អត់បានដឹងអីនឹងគេទេ ខ្ញុំចេញឡើងទៅដល់កន្លែងថ្នល់ឃើញប្រជាជនច្រើនណាស់ គេគ្រាន់ថាឲ្យបញ្ជូន បញ្ជូនទៅខ្ញុំអត់បានបញ្ជូនអីនឹងគេផង ។ ខ្ញុំនេះគេដឹកឡើងទៅកំពង់សោមនេះមៅមកនៅត្រឹមកងកេង ខ្ញុំឡើងមកកំពង់សោមកាលហ្នឹង ។

ដានី ៖ ចុះពូអត់បានឃើញទិដ្ឋភាពគេជម្លៀសប្រជាជនអីចេញទេ?

សំអុន ៖ ឃើញតាស់ ឃើញតាមផ្លូវខ្ញុំជិះឡានតាមផ្លូវ មិនដឹងថាយ៉ាងណាយ៉ាងណីអត់ដឹង ។

ដានី ៖ ថ្ងៃណាពូមានចាំថ្ងៃដែលគេបញ្ជូនពូមកកន្លែងកងកេងនេះទេ?

សំអុន ៖ ថ្ងៃហ្នឹងគឺមិនចាំតែទេ ព្រោះខ្ញុំប្រហែលជាបានថ្ងៃក្រោយពីរំដោះ ។

ដានី ៖ ក្រោយរំដោះបាន៣ថ្ងៃ?

សំអុន ៖ ៣ថ្ងៃហ្នឹងឲ្យមៅ ហើយខ្ញុំនៅតាកន្លែងផ្ទះទេ អត់បានឡើងថ្នល់ទេ ឃើញតែប្រជាជនហូរហែរចឹងមើលឃើញនៅតាមថ្នល់ ពីភូមិទៅថ្នល់ជិតដែរហ្នឹង ។ វាជិតដែលឃើញតែប្រជាជនដើរហូរហែរតាមហ្នឹង មិនដឹងជាយ៉ាងណាយ៉ាងណីទេ ។

ដានី ៖ ពូអាចរៀបរាប់ទេថាមូលហេតុអីបានជាគេផ្លាស់ពូពីកំបូលហ្នឹងមកកន្លែងកងកេងវិញ?

សំអុន ៖ ខ្ញុំមិនបានដឹងទេពិតដែលថាតាមពិតកងពលទី៣ត្រូវមកហ្នឹងទាំងអស់ តែរឿងរ៉ាវយ៉ាងម៉េចមិនដឹងទេ តែពល៣ត្រូវតែបញ្ជូនមកខាងហ្នឹង មកនៅខាងហ្នឹងទាំងអស់ ។

ដានី ៖ នៅកន្លែងកងកេងហ្នឹង?

សំអុន ៖ បានមកនៅកងកេងហ្នឹង ។

ដានី ៖ ដំបូងធ្វើអីទៅនៅកន្លែងហ្នឹង?

សំអុន ៖ ខ្ញុំមកនៅកងកេងដំបូងគេឲ្យម៉ាកងខ្ញុំហ្នឹងជួសជុលផ្លូវរទេះភ្លើងពីត្រពាំងល្ពៅមកកំពត ។

ដានី ៖ ត្រពាំងល្ពៅ?

សំអុន ៖ បាទ ។

ដានី ៖ នៅណាទៅត្រពាំងល្ពៅ?

សំអុន ៖ ត្រពាំងល្ពៅនៅហួសព្រៃក្គាត ។

ដានី ៖ ព្រៃក្គាត នៅខេត្តកំពតយើងហ្នឹង?

សំអុន ៖ តាមផ្លូវហ្នឹងឃើញហើយត្រពាំងល្ពៅ ពីដើមជាកន្លែងធ្វើទឹកត្រី ។

ដានី ៖ ម៉ាកងហ្នឹងពូសំដៅលើប៉ុន្មាននាក់?

សំអុន ៖ ម៉ាកងហ្នឹង កងអនុសេនាតូចរបស់ខ្ញុំ ។

ដានី ៖ គេឲ្យនៅជួសជុល?

សំអុន ៖ នៅជួលជុលរហូតប្រមាណប្រហែលជា១ខែជាងទំរាំនឹងហើយ ជួសជុលតាំងពីត្រពាំងល្ពៅមកកំពង់ចិន មកដល់កំពតយើងមក ។

ដានី ៖ កាលហ្នឹងផ្លូវអាទេះភ្លើងខូចអី?

សំអុន ៖ ខូចចុះខ្មែរក្រហមកាលហ្នឹងសង្គ្រាមគេមិនកាត់អាទេះភ្លើងអីផ្លូវអីចោលអស់ តាផ្លូវលំ ផ្លូវជាតិហ្នឹងក៏គេកាយកុំឲ្យឡានឆ្លងកាត់បានដែរ ហើយអាទេះភ្លើងក៏ត្រូវដាច់មុិតហើយ អត់មានឲ្យឆ្លងកាត់បានទេ ។

ដានី ៖ ដល់ពេលចឹងគេឲ្យយើងមកជួសជុលត?

សំអុន ៖ បាទ!ជួសជុលតវិញ ។

ដានី ៖ ធ្វើឡើងវិញ?

សំអុន ៖ ខូចហើយធ្វើវិញ ។

ដានី ៖ ធ្វើរយៈពេលប៉ុន្មានទៅ?

សំអុន ៖ ខ្ញុំប្រហែលជា២ខែជាងហើយ បានមិនដល់២ខែទេ ហើយពីហ្នឹងទៅគេដកខ្ញុំទៅវិញ ហើយពួកកងខ្ញុំគេរំលាយអស់ហើយ អត់មានទេ ខ្ញុំក៏ចប់ឈ្មោះជាភារកិច្ចទៀតហើយ គេបញ្ជូនខ្ញុំទៅសមុទ្រ ទៅកំពង់សោម ទៅហ្នឹងទៅយកតាមេៗត្រឹមអនុសេនាតូច ទៅអនុសេនាធំ វរសេនាធំយកប្រធានៗទេ ហើយតក្រោយមកទៀតបានឃើញចេញមកមានមេក្រុមមានអនុមានអីៗបន្តទៀត ។

ដានី ៖ កាលហ្នឹងពូតួនាទីអីគេ?

សំអុន ៖ ខ្ញុំត្រឹមជាអនុសេនាតូចទេ ដល់នោះដល់ដើងទឹកមេក្រុមហើយ ចុះគ្នាអនុសេនាធំមក អនុសេនាតូច គេចុះម៉ាថ្នាក់ៗចឹងទៅ ។

ដានី ៖ អញ្ចឹងពេលពូមកដល់កន្លែងកងកេងហ្នឹងពូជាប្រធានអនុសេនាតូច?

សំអុន ៖ បាទៗ ។

ដានី ៖ ចឹងយ៉ាងម៉េច ពូដឹងពីផែន គោលការណ៍គេផ្លាស់យើងពីកន្លែងកងកេងហ្នឹងទៅសមុទ្រ?

សំអុន ៖ គ្មានចាប់អារម្មណ៍ ហើយគ្មានដឹងអីទេ គឺថាចាត់យ៉ាងណាធ្វើយ៉ាងណឹងហើយខ្ញុំ ខ្ញុំមិនបានចង់ដឹងរឿងរ៉ាវរបស់គេបើគេឲ្យធ្វើណាគឺត្រូវតាធ្វើស្តាប់ខ្លួនឯងថាយើងជាអញ្ចឹងយើងត្រូវស្តាប់បញ្ជាគេ មេចាត់ចែងទៅណាយើងទៅហ្នឹងទៅ ។

ដារ៉ា ៖ កងពលទី៣ទាំងអស់ដែលត្រូវទៅកន្លែងកងកេង?

សំអុន ៖ បាទ! ទៅដល់កន្លែងហ្នឹងតគាមូលគ្នាបានដឹងថាកងពលទី៣ទាំងអស់ ។

ដារ៉ា ៖ ហើយស្ថិតក្រោមការគ្រប់គ្រងរបស់មាសមុតដដែល?

សំអុន ៖ បាទៗ ។

ដារ៉ា ៖ គាត់ទៅគ្រប់គ្រងហ្នឹងត?

សំអុន ៖ បាទៗ ។

ដានី ៖ ចុះផែនការដែលយើងផ្លាស់ពីកងកេងទៅសមុទ្រនោះ ពូអាចរៀបរាប់?

សំអុន ៖ កាលហ្នឹងខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំទៅតាខ្ញុំចឹងទៅ គេទៅតាគេ ហើយទៅជួបគ្នានៅម្តុំកន្លែងនោះ គេហៅថាម្តុំអូរឈើទាលហ្នឹង តំបន់សមុទ្រហ្នឹង នៅតាមផ្ទះៗ ទៅដល់ឃើញសុទ្ធតាគ្នាយើងមកពីនោះ ។ កាលមកអត់មានជួបគ្នាទេដល់កន្លែងនោះជួបគ្នា ជួបគ្នាសុទ្ធតាដើរវៃអីៗមួយគ្នាហ្នឹង ស្គាល់គ្នាអានេះជាប្រធានអនុសេនាតូច អានេះជាមេក្រុមអីហ្នឹងយើងស្គាល់គេ ចឹងស្គាល់ឋានៈគេ ។

ដានី ៖ តែកងពលទី៣ នៅជាកងពលទី៣ដដែល ឬក៏គេមានប្រែឈ្មោះអី គេដូរអីយ៉ាងម៉េច?

សំអុន ៖ អត់គឺកងពលទី៣ចឹងម្តង អត់មានប្រែឈ្មោះថាអីៗទៀតក្រែងលម៉េចទៀតខ្ញុំមិនដឹង តែខ្ញុំដឹងថាកងពលទី៣ កន្លែងហ្នឹងឈ្មោះទៅមុនដំបូងមិនទាន់បានហែលទឹកហែលអីទេ យើងនៅជួយធ្វើទំនប់អូរឈើទាលខ្លះ ជួយធ្វើខ្លះទៅហើយដល់ពេលរសៀលអីទៅហ្វឹកហ្វឺនហែល ទឹកហែលអីពិតតាហ្វឹកហ្វឺនចែកជាកម្លាំងតែកម្លាំងចែកទៅតដាក់ស្តែងសិនណាៗហែលបាន វៃងជាងគេទៅអាណើងទីមួយ អាណាហែលបានកណ្តាលទៅ អាណើងទី២ អាណាហែលបានជិតជាងគេទៅអាណើងទី៣ទៅ ទីមួយក្បាលគេពិនមេដៃ អាទី២ក្បាលពិនជន្ទល់ ដល់អាទី៣ ក្បាលពិនយើងអាដែល ។

ដានី ៖ ចុះពូកាលហ្នុងដូចជាថាកាលពេលដែលយើងទៅដល់កំពង់សោម យើងចាប់ផ្តើមរៀនសូត្ររៀននយោបាយ ហ្វឹកហាត់អីយ៉ាងម៉េច មានផែនការអីយើងត្រូវធ្វើ?

សំអុន ៖ គ្មានហ្វឹកហាត់ គ្មានលូន គ្មានក្រាបអីទៀតទេ អត់មានទាន់សោះកាលជំនាន់ហ្នឹង ឃើញតាហ្វឹកហ្វឺនគឺហែលទឹក តែហែលទឹកណើងខ្ញុំមិនចេះនឹងគេទេ ខ្ញុំទី៣រហូត ទី៣ហើយមានពោងទៀត

ដានី ៖ ចុះអត់មានរៀនសូត្រអីពីគោលនយោបាយ?

សំអុន ៖ អត់ទេ!នយោបាយអត់មានទាន់រៀនសូត្រអីផង ។

ដានី ៖ នយោបាយអត់មានរៀន?

សំអុន ៖ បាទ!នៅទេ ទៅនៅមានតែប្រជុំប្រជរ អារឿងធ្វើការយើង ហ្វឹកហ្វឺនហាត់ចេះចុះតិចតួចហ្នឹងវាគ្មានថារៀនសូត្របំពាក់បំប៉នថាយើងជាអីអត់ទេ ។

ដានី ៈ  ចុះកាលហ្នឹងតាមុត  គាត់ជាប្រធានកងពល  ចុះថាដូចជាអនុសមាជិកអីគណៈកងពលគេមានគ្នាគេបីបួននាក់?

សំអុន ៈខ្ញុំអត់ស្គាល់អស់ មាន៣នាក់ ខ្ញុំស្គាល់ឈ្មោះតាឆានមួយដែរ ពិនមិនសូវដែលឃើញ ។

ដានី ៈ  តាឆាន?

សំអុន ៈបាទ!ហើតាឌីមមួយដែរ ។

ដានី ៈ  តាឆាន តាឌីម?

សំអុន ៈបាទ!៣នាក់ហ្នឹង តែតាឌីម គាត់មានដែលទៅបើកវគ្គសាលាដែរ បើកវគ្គរៀនសូត្រ ។

ដានី ៈ  តាឌីមគាត់មកពីណា?

សំអុន ៈមកពីកាលហ្នឹងមកពីខាងបូព៌ា ។

ដានី ៈ  តាឆាន?

សំអុន ៈតាឆានអត់ដឹង ។

ដានី ៈ  ចុះពូមិញពូមានប្រសាសន៍ថាម៉ាកន្ទែងកងកេងសុទ្ធតែកងពលទី៣ទាំងអស់?

សំអុន ៈបាទៗ ។

ដានី ៈ  កងពលទី៣ កងពលរបស់នីរតី?

សំអុន ៈរបស់នីរតី ។

ដានី ៈ  ចុះពូមានប្រសាសន៍មិញ តាឌីមគាត់មកពីបូព៌ាយ៉ាងម៉េចដែរ?

សំអុន ៈគឺអាហ្នឹងគេថាកងចំរុះ  តែមិនដឹងម៉េចទេគម្រោងការថ្នាក់លើ  ពិនតែឃើញឈ្មោះគាត់មកដល់ហ្នឹងដែរ កាលហ្នឹងអ្នកបានស្គាល់គេនិយាយគ្រប់គ្នាថា តាឆាន តាឌីម តាមុត យើងហ្នឹង ។

ដានី ៈ  ចឹងមានន័យថាពេលដែលពូទៅដល់អូរឈើទាលហ្នឹង គឺមានកងទ័ពខាងបូព៌ាគេម៉ោដែរ?

សំអុន ៈម៉ោដែរតាស់ ។

ដានី ៈ  ម៉ោដែរ?

សំអុន ៈបាទ ។

ដានី ៈ  ចឹងវាចំរុះសុទ្ធតែកងពលទី៣?

សំអុន ៈចំរុះគ្នា  កាលហ្នឹងចំរុះហើយ  ខ្ញុំបាននៅម៉ាជួបចំរុះគ្នាហ្នឹង  ខ្ញុំទៅនៅហ្នឹងកោះវិញហើយ  អ្នកចំរុះហ្នឹង  ខ្ញុំក៏ទៅកោះ  គេក៏ទៅកោះទៅទាំងអស់គ្នាខាងបូព៌ាហ្នឹង  ទៅកោះហៅកោះរោងសន្ទឹមឆកសាលាសេនកោះរោងតូច កោះរោងក្នុង មែនអាកោះរោងធំនោះទេ កោះរោងមានពីរ ពិនអាមួយរោងសន្ទឹម  រោងសន្ទឹមនឹងមានឆកមួយ  ហៅថាឆកសាលាសេន ។

ដានី ៖ ចឹងដល់ពេលយើងទៅរួមគ្នាអត់មានដូរឈ្មោះកងពលកងអីទេ?

សំអុន ៖ អត់ទេ!អត់មានដូរទេ នៅកងពលទី៣ដដែល ។

ដានី ៖ កងពលទី៣?

សំអុន ៖ បាទ ។

ដានី ៖ ទោះជាពួកបូព៌ាអីម៉ោក៏ដោយ?

សំអុន ៖ អត់ទោះបីជាម៉ោក៏ដោយនៅកងពលដដែល ក្រោយមកទៀតខ្ញុំក៏គេហៅឡើងមករៀនសូត្រ ។

ដានី ៖ ចុះពូៗមានប្រសាសន៍មិញថាយើងមកកន្លែងអូរឈើទាល ពូហាត់ហែលទឹកអីរយៈពេលប៉ុន្មានទៅបានពូទៅកោះ?

សំអុន ៖ ខ្ញុំប្រហែលជាម៉ាខែម៉ាខែជាង ។

ដានី ៖ ម៉ាខែជាង?

សំអុន ៖ បាទ ។

ដានី ៖ នៅក្នុងឆ្នាំ៧៥ដដែល?

សំអុន ៖ បាទ ។

ដានី ៖ ខែប៉ុន្មានទៅដែលគេបញ្ជូនពូទៅកោះ?

សំអុន ៖ បញ្ជូនទៅកោះ ក្នុងខែហ្នឹង ខ្វង់ខែចុងខែ៤ហើយ ។

ដានី ៖ ចុងខែ៤?

សំអុន ៖ បាទ!ចុងខែ៤ ។

ដានី ៖ ចុះពូកាលហ្នឹងពូដែលដឹងរឿងទាក់ទងហ្នឹងកប៉ាល់ម៉ាចាយ៉េស?

សំអុន ៖ ម៉ាចាយ៉េសបានលឺសូរពិនខ្ញុំអត់នេះបានស្តាប់វិទ្យុតិចៗ ខ្ញុំមិនចាប់អារម្មណ៍ទេ នឹកឃើញតាអាមេរិចកាំងវ៉ាសាវែល ទម្លាក់នៅរៀមនៅអីហ្នឹង ។

ដានី ៖ កាលហ្នុងពូនៅណា កាលដែលអាមេរិចកាំងមកទម្លាក់អីៗហ្នឹង?

សំអុន ៖ ម៉ាចាយ៉េស ហ្នឹងខ្ញុំនៅកំពង់សោម ។

ដានី ៖ កំពង់សោមនៅកន្លែងហាត់ហែលទឹកហែលអីហ្នឹង?

សំអុន ៖ នៅកំពង់សោម ហ្នឹងហើយនៅកំពង់សោម កាលហ្នុងខ្ញុំស្តាប់សូរឈ្មោះកាលខេងតវ៉ា ឈ្មោះរដ្ឋមន្ត្រីយើងនៅក្រសួងសាធារណៈការជិនទាន់ហ្នឹងឈ្មោះអី ឈ្មោះអ្នូរ..ហ៊ូ នឹម គាត់តវ៉ាជាមួយគ្នាអាមេរិចកាំងរឿងអាម៉ាចាយ៉េសហ្នឹង ហ្នឹងខ្ញុំនៅក្នុងស្រុកទេ ខ្ញុំមិនទាន់ទៅណាទេ ។

ដានី ៖ ចុះពូអាចកន្លែងទាក់ទងពីរឿងវ៉ាំវកប៉ាលម៉ាចាយ៉េសហ្នឹង ហេតុអីបានជាមានអាមេរិចការំងមក ទម្លាក់ហ្នឹង ពូដឹងពីមូលហេតុដំបូងមូលហេតុយ៉ាងម៉េច?

សំអុន ៖ មិនដឹងសោះ ខ្ញុំអត់ដឹងទេពីរឿងហ្នឹង ។

ដានី ៖ អត់ដឹងទេ?

សំអុន ៖ បាទ!អត់ដឹងទេ តែខ្ញុំធ្លាប់បានមើលកាសែត តែខ្ញុំភ្លេចអស់ហើយ ខ្ញុំមើលកាសែតអាខេងសុងលីកូលហ្នឹង ខ្ញុំមើលឃើញពីបញ្ហាម៉ាចាយ៉េសអីហ្នឹងខ្ញុំមានទំនាក់ទំនងអាហ្នឹងដែរ ដឹងឆ្នាំណាម៉ោណាកាសែតហ្នឹង ។

ដានី ៖ កាសែតក្រោយនេះទេអាឡូវៗនេះដែរ?

សំអុន ៖ មិនដឹងកាសែតពីឆ្នាំណា មិនបានមើលវាដាច់ដោចអស់ហើយ ។

ដានី ៖ ប៉ុន្តែបើពូផ្ទាល់វិញពូដែលធ្លាប់?

សំអុន ៖ អត់ដឹងទេ ខ្ញុំអត់ដឹងទេ ។

ដានី ៖ អត់ដែលដឹងទេ?

សំអុន ៖ បាទ!អត់ដែលដឹងទេ ខ្ញុំអត់បានទាក់ទិនរឿងហ្នឹង ។

ដានី ៖ ចុះមួយទៀតទាក់ទងនឹងរឿងកាលកងទ័ពយើងទៅវ៉ៃនៅកោះត្រល់ហ្នឹងពូមានដែលដឹងរឿង?

សំអុន ៖ អត់ដឹងដែរ ។

ដានី ៖ អត់ដឹងដែរ?

សំអុន ៖ បាទ!អត់ដឹងអីទេ ។

ដានី ៖ ព្រោះឆ្នាំ៧៥ ថាកងទ័ពនៅខាងកំពង់សោមហ្នឹងមានបញ្ជូនម៉ាវរសេនាតូចទៅខាងកោះត្រល់?

សំអុន ៖ មិនមែនពួកខ្ញុំដឹង ។

ដានី ៖ មែន?

សំអុន ៖ បាទ!បើមែនពួកខ្ញុំគឺមិនដឹងទេ ។

ដានី ៖ ចឹងពូអាចរៀបរាប់បន្តទៀតដែលពូទៅកោះរោងសន្លឹមនោះ ហើយយ៉ាងម៉េចទៀតទៅ?

សំអុន ៖ អត់មានអីទេនៅហ្នឹង នៅនោះខ្ញុំអត់មានធ្វើអីផង ធ្វើចំការ ទៅក្រោយអាចំការចាស់ៗប្រជាជន នៅតាមចំការដូងចំការអីហ្នឹង ទៅក្រោយវាឲ្យវាលទៅ អត់មានប្រជាជននៅហ្នឹងទេ ធ្វើតាហ្នឹងធម្មតាអត់មានធ្វើអីទៀតទេ ។

ដារ៉ា ៖ ចុះពូនិយាយពីសិទ្ធអំណាចរបស់មាស មុត នៅក្នុងកងពលទី៣ហ្នឹង គឺថាមានសិទ្ធអំណាចគ្រប់គ្រងដល់ណាទៅ ដល់កងទ័ពកងពលទី៣ រឺក៏ជាការគ្រប់គ្រងអំណាចពេញម៉ាកំពង់សោមចឹង?

សំអុន ៖ ហ្នឹងខ្ញុំអត់សួរដឹងច្បាស់ដែរ ប្រហែលជាអញ្ចឹងមែនដឹងព្រោះកន្លែងគាត់គ្រប់គ្រងវា ពិនមាន ឈ្មោះខាងសុខាភិបាលវាផ្សេង គេមានពេទ្យមានអី អើពិនពេទ្យ ពេទ្យកងពលដែរ អញ្ចឹង ប្រហែលជាគាត់គ្រប់គ្រងទាំងអស់ហ្នឹង ព្រោះកាលហ្នឹងមិនទាន់មានកងណាចូលប្រឡូកប៉ូកប៉ាក អីទេ សុទ្ធតែចំណុះកងពលទាំងអស់ទាំងកងដឹកជញ្ជូន ទាំងកងសុខាភិបាល ទាំងកងទ័ពទាំងអស់ ហីកងទ័ពហ្នឹងដែលខ្ញុំដឹង កងទ័ពម្ដុំពួកខ្ញុំនេះក្លាយជាកងទ័ពជើងទឹកហើយ ដាក់ឈ្មោះជាកងទ័ព ជើងទឹកបាត់ហើយ ។

ដានី ៖ កងទ័ពជើងទឹក?

សំអុន ៖ បាទ ។

ដារ៉ា ៖ ចឹងមានន័យថាម៉ាកំពង់សោមហ្នឹងស្ថិតក្រោមការគ្រប់គ្រងរបស់មាស មុត ទាំងអស់?

សំអុន ៖ បាទៗ ។

ដានី ៖ ទាំងកងជើងទឹក កងសុខាភិបាលកងស្អីៗ?

សំអុន ៖ បាទៗ!កងដឹកជញ្ជូនអី នារីនារ៉េញអីទាំងអស់ ។

ដានី ៖ តែការហ្នឹងមានកម្មករកំពង់ផែ មានក្រុមខាងនេសាទអីដែរ?

សំអុន ៖ កំពង់ផែខាងនេសាទអីហ្នឹងខ្ញុំអត់ដឹងសោះ ខ្ញុំនៅអូរឈើទាល ដឹងថាពេល ពេលដល់ពេល ជិត ម៉ោងបាយអីហ្នឹងឃើញគេដឹកត្រីយកមកដាក់កន្លែងខ្ញុំឲ្យគេធ្វើត្រី ធ្វើអីហូបចឹងតួវបានអ្នកណា ធ្វើស្អីក៏ខ្ញុំអត់ដឹងដែរ ដឹងតែភារកិច្ចខ្លួនឯង ។

ដានី ៖ ចុះពូអាកោះរោងសន្លឹមអីហ្នឹង វានៅឆ្ងាយៗពីកោះ ដូចជាកោះពូលូវ៉ៃ កោះតាងអី នៅជិត គ្នារឺក៏ឆ្ងាយពីគ្នា?

សំអុន ៖ បាទ!ឆ្ងាយៗពីគ្នាណាស់ កោះនៅឆ្ងាយៗពីគ្នា កោះរោងសន្លឹមជិតជាងគេ កោះថាស កោះដែកគោល កោះអីហ្នឹងវាជិតជាងហ្នឹងទៀត កោះពស់ កោះអីហ្នឹងវាជិតកំពង់សោម វាឃ្លាតពីហ្នឹងតិចទៀតទៅបានដល់កោះរោងសន្លឹម ហ្នឹងទិសដៅដែលខ្ញុំទៅហ្នឹងហី ឃ្លាតពីហ្នឹង តិចទៀតបានកោះរោងធំ ។

ដានី ៖ ចុះពីកោះរោងធំហ្នឹង ទៅកោះពូលូវ៉ៃ កោះតាងអី ឆ្ងាយៗពីគ្នា?

សំអុន ៖ ឆ្ងាយណាស់! បាទ! នៅឆ្ងាយណាស់ ។

ដានី ៖ ចុះពូនៅកោះហ្នឹងរយៈពេលប៉ុន្មានបានគេដកមក?

សំអុន ៖ ខ្ញុំនៅមិនដល់ម៉ាខែផង ម៉ាខែហ្នឹងខ្ញុំគ្រុន កើតជម្ងឺគ្រុនចាញ់ខ្លាំងណាស់កាលហ្នឹងឈឺជម្ងឺគ្រុន ចាញ់ខ្លាំងមែនទែនមានអ្នកខ្លះស្លាប់ កងទ័ពយើងហ្នឹងស្លាប់ដោយសារកើតជម្ងឺគ្រុនចាញ់ ដល់

ក្រោយមកមានបានមានការទប់ទល់ទាន់ មានបាញ់ថ្នាំបាញ់អីៗខ្ញុំក៏មកព្យាបាលជម្ងឺព្យាបាលជម្ងឺហើយថ្មើហ្នឹងខ្ញុំត្រឡប់ទៅវិញ ។ ត្រឡប់ទៅវិញបានប៉ុន្មានថ្ងៃគ្រួសារខ្ញុំទៅលេង ហើយខ្ញុំក៏មកជួប កាលហ្នឹងអត់មានកប៉ាល់មានអីពីដើមគេហៅប៉េអឺ ប៉េអឺ ហ្នឹងជិះម៉ៅឈើធ្វើពីឈើពិនតែទូកវាធំសម្រាប់ទូកបុកចាយទូកខ្ទេងឆ្លងទឹកត្រឡប់មកជួបហ្នឹង ។ ជួបហ្នឹងប្រធានវរសេនាធំឈ្មោះ ហន ប្រាប់ខ្ញុំថាបងឯងប្រហែលទៅរៀនបច្ចេកទេស៧៥ហើយហ្នឹង ៧៥ ហើយថាបងឯងប្រហែលទៅរៀនបច្ចេកទេសហើយមិនដឹងក្នុងស្រុករឺក្រៅស្រុកទេ បានគ្រាន់តែប្រាប់ប៉ុណ្ណឹង ។

ដានី : ចឹងកាលពូនៅកោះរោងសន្ទឹមហ្នឹងគ្នាប៉ុន្មាននាក់?

សំអុន : នៅហ្នឹងម៉ាកងវរៈ ។

ដានី : កងវរៈកងវរសេនាតូច?

សំអុន : បាទ!កងវរសេនាតូច ។

ដានី : ឈ្មោះ សាធ ហ្នឹងមែន?

សំអុន : អត់ទេ!ឈ្មោះសាធ ហ្នឹងបែកគ្នាតាំងពីភ្នំពេញម៉េះ មកដល់ខ្ញុំមកនៅមួយឈ្មោះ ហន វិញហើយ ។

ដានី : ឈ្មោះ ហន វិញ?

សំអុន : បាទ!ឈ្មោះ ហន វិញគាត់មកដើងទឹកមួយគ្នាផ្តុំគ្នាវិញ ប្រមូលផ្តុំគេរៀបចំជាថ្មី ដូចខ្ញុំជំ រាបចឹង គេដកពីនេះមួយពីនោះមួយមករៀបចំជាកងទ័ពដើងទឹកហ្នឹងម៉ោ មេថ្នាក់អនុសេនាតូចមកមេក្រុមមកអនុសេនាធំក្លាយទៅជាអនុសេនាតូចមៅ បានចុះម៉ាថ្នាក់ៗចឹងទាំងអស់បានគេរៀបចំជាថ្មី ។

ដានី : ចឹងកាលហ្នុងមីងគាត់នៅណា?

សំអុន : នៅស្រុកនេះ ។

ដានី : មីងអត់ទៅនៅជាមួយពូទេ?

សំអុន : អត់ទេ ។

ដានី : ចុះកាលហ្នុងមីងគាត់ទៅលេងពូនៅកំពង់សោម?

សំអុន : បាទៗ ។

ដារ៉ា : ដើរហើរម៉េចកើតទៅ?

សំអុន : អូរប្រពន្ធខ្ញុំដើរហើរកើត ដូចកងរឺចឹង ។

ដានី ៖  ដូចចង់និយាយថាលិខិតស្នាម ដើរហើរ ការអនុញ្ញាតអី?

ប្រពន្ធសំអុន ៖ អត់កាលហ្នុងលួចសុំគេទៅ  កាលហ្នុងយើងពុងវែកដីដំបូក  ដីអីដាក់ស្រែ  ធ្វើទំនប់ធ្វើប្រឡាយអីចឹង ។

ដារ៉ា ៖  ចឹងលួចទៅចឹង?

ប្រពន្ធសំអុន ៖ លួច លួចសុំគេ ។

ដានី ៖  កាលហ្នុងមឹងសុំពីណាគេទៅ?

ប្រពន្ធសំអុន ៖ សុំប្រធានភូមិ

ដានី ៖  ប៉ុន្តែបើមឹងផុតពីភូមិហ្នឹងចូលភូមិគេផ្សេង ដល់ឃុំគេផ្សេង យើងសុំម៉េច?

ប្រពន្ធសំអុន ៖ អត់បេះតែទៅរួចរហូត អត់មានណាគេសួរអីតាមផ្លូវផង ។

ដានី ៖  អត់មានសំបុត្រគេធើសំបុត្រឲ្យទេអូរ?

ប្រពន្ធសំអុន ៖ អត់ទេ ។

ដានី ៖  អត់ទេ?

ប្រពន្ធសំអុន ៖ ចាស ។

ដានី ៖  ចុះពូកាលហ្នុងគ្រូនចាញ់ពូម៉ោព្យាបាលនៅណា នៅកំពង់សោម?

សំអុន ៖ នៅកំពង់សោម បាទ ។

ដានី ៖  រយៈពេលប៉ុន្មានទៅកាលហ្នុង?

សំអុន ៖ ម៉ាអាទិត្យ

ដានី ៖  ម៉ាអាទិត្យ?

សំអុន ៖ បាទ!ម៉ាអាទិត្យចេញម៉ោក៏បានជាល្មមៗ ខ្ញុំដើររៀងស្រួលបួលហើយបានគេហៅទៅភ្នំ ពេញទៀតដល់ពេលហ្នឹងមុននឹងចេញទៅគេរៀនសូត្រហើយ ប៉ុណ្ណឹងគេប្រាប់ច្បាស់ថែស ហើយពេលហ្នឹងប្រាប់ថានែ៎យើងទៅរៀនបច្ចេកទេសហ្នឹងទៅរៀនស្រុកគេទេ ស្រុកចិនទេ ដូច្នេះរៀបចំខ្លួនប្រាណគំនិតគិតគូរអីធ្វើអីឲ្យវា ។ អាហ្នឹងគេហៅថាពាក្យណែនាំពាក្យ គេណែនាំឲ្យយើងបានត្រឹមត្រូវ អាហ្នឹងគេនិយាយត្រឹមត្រូវ ។

ដានី ៖  ពូមានប្រសាសន៍មិញដូចថា គេរើសទៅរៀនបច្ចេកទេសនឹងពូ អាចដឹងថាកាលហ្នុងយើងមានលក្ខណៈសម្បត្តិយ៉ាងម៉េច បានគេជ្រើសរើសយើងឲ្យទៅរៀន?

សំអុន ៖ កាលទៅហ្នឹងមានលក្ខណៈសម្បត្តិមិនទៀងទេ គិតតាពីសុខភាពសិន ។

ដានី ៖  សុខភាព?

សំអុន ៖ បាទ!សុខភាពគេពិនិត្យល្អិតល្អន់មែនទែន តាំងពីរាងរូវទាំងអស់ តាំងពីភ្នែក តាំងពីច្រមុះ តាំងមាត់ ទាំងសរសៃរសសួង តាំងផ្លូវលាមកយើងហ្នឹងផ្លូវបត់ជើងបត់ដៃពងអី១ គេពិនិត្យត្រឹមត្រូវរបស់គេត្រឹមត្រូវទាំងអស់ដែរ ថាគ្រប់លក្ខណៈហើយបានគេឲ្យយើងទៅ ។

ដានី ៖ អាហ្នឹងគេពិនិត្យចឹង ចុះមុនហ្នឹងដើម្បីជ្រើសរើសបានទៅពិនិត្យដូចថាអ្នកហ្នឹងមានលក្ខណៈសម្បត្តិយ៉ាងម៉េច ដូចជាវណ្ណៈភាពស្អាតស្អំ យើងមានតួនាទីអីយ៉ាងម៉េចបានគេជ្រើសទៅ?

សំអុន ៖ ខ្ញុំអត់បានចាប់អារម្មណ៍ទេ កន្លែងហ្នឹង ព្រោះគេប្រឡូកប៉ូកប៉ាក់ កន្លែងហ្នឹងហាក់ដូចជាគេចំពាញ់ហើយបាត់ហើយ បានកងពលពាហ្នឹងពួកជើងទឹកហ្នឹងដូចជាគេស្រាវជ្រាវពីកន្លែងថ្មើរជើងពីមុនថ្មើរជើង ។ ដកមួយ១ទៅនៅហ្នឹង ដូច្នេះប្រហែលជាពេលហ្នឹងគេមិនបានជ្រើសរើសទៀតក៏មិនដឹងដែរ ព្រោះគេតាមដានរហូតហើយ អាហ្នឹងខ្ញុំស្មានទេ ព្រោះខ្ញុំមិនបានគិតគូរដល់ហ្នឹង ។

ដានី ៖ គ្នាប៉ុន្មាននាក់ទៅដែលជ្រើសរើសចេញទៅរៀន?

សំអុន ៖ ចេញទៅហ្នឹង កាលខ្ញុំចេញទៅដំបូងគេហ្នឹង ខាងជើងទឹក គឺគេអត់មានយកទាហានទៅទេ គឺយកតែអ្នកបច្ចេកទេស អ្នកជួសជុលទូនាវាហ្នឹងមែនទូនាវាទេ ខ្ញុំបានជិះទូនាវា ហើយគេក្រៅពីហ្នឹងម៉ាស៊ីនអី១ហ្នឹង លើនាវាទាំងអស់៤៥នាក់ ។ ហ្នឹងអ្នកបច្ចេកទេសទាំងអស់ត្រូវទៅរៀនហើយម៉ោវិញបង្រៀនគេទៀត ។ បានយើងទៅរៀនហើយឲ្យចេះហើយណា មកបង្រៀនគេជាកម្មករកម្មអីឲ្យធ្វើនេះទៀតទៅ៤៥នាក់ ដល់តាខ្ញុំទៅប្រហែលម៉ាខែ ទើបឃើញបញ្ជូនមានកងទ័ពទៅកងទ័ពទៅ ។ កងទ័ពដែលទៅយកកប៉ាល់អីមកស្រុកវិញ គេទៅប្រហែលជាម៉ាឆ្នាំគេម៉ោវិញ គេហ៊ឹកហ៊ឺនហើយ ហ៊ឹកហ៊ឺនហាត់ខាងកាន់កាប់កប៉ាល់ហ្នឹងបានមិនបានអ្នកកាន់ពួរកាន់ម៉េច អ្នកយុទ្ធការអាម៉េច កាន់កាំភ្លើងកាន់អាម៉េច កាន់ម៉ាស៊ីន កាន់ម៉េចហ្នឹង គេហ៊ឹកហ៊ឺនអាហ្នឹងហើយអស់បានគេបញ្ជូនកប៉ាល់ហ្នឹងមកស្រុកខ្មែរ តែខ្ញុំនៅស្រុកចិនដែលទេ ។

ដានី ៖ ចុះពូថ្ងៃណាដែលពូ ដែលគេជ្រើសរើសឲ្យពូចេញទៅហ្នឹងថ្ងៃខែ?

សំអុន ៖ អាហ្នឹងខ្ញុំចាំជាប្រវត្តិសាស្ត្រហើយម៉ាជីវិតខ្ញុំដែលចេញពីស្រុកខ្មែរគឺថ្ងៃ២៧ខែ៧ ឆ្នាំ១៩៧៦

ដានី ៖ ថ្ងៃទី២៧ខែ៧ឆ្នាំ១៩៧៦?

សំអុន ៖ បាទ ។

ដានី ៖ ចុះមុនពេលចេញទៅគេពិនិត្យដូចពូមានប្រសាសន៍មិញពិនិត្យសុខភាពរាងកាយយើង អាហ្នឹងគេពិនិត្យនៅកន្លែងណាដែរ?

សំអុន ៖ ពិនិត្យនៅកំពង់សោមកន្លែងហ្នឹងគេមានចឹង ។

ដានី ៖ នៅកំពង់សោម?

សំអុន ៖ បាទ!គេមានឋានៈរបស់គេពីមុនៗ មៅ៉ គេមានឋានៈគេឋានៈដុកទ័រដែរគេអ្នកចេះដឹង ឈ្មោះតាសុកៗគាត់ចេះដឹងជ្រៅជ្រះណាស់ ។

ដានី ៖ តាសុកហ្នឹងគាត់នៅពេទ្យ?

សំអុន ៖ នៅពេទ្យកងពលតែម្ដងជាប្រធានពេទ្យ ។

ដានី ៖ ជាប្រធានពេទ្យកងពល?

សំអុន ៖ បាទ!គាត់មកពិនិត្យហ្នឹងទាំងអស់ នៅកន្លែងហ្នឹងទាំងវះកាត់ទាំងអីៗ គេធ្វើម៉ាចប់គ្រប់គ្រាន់ទាំងអស់គ្រាន់តែវាអត់ទាន់សម័យ ។

ដានី ៖ ពិនិត្យហើយយ៉ាងម៉េចទៀត គេបញ្ជូនមកភ្នំពេញឬបញ្ជូនទៅណា?

សំអុន ៖ អត់មានបញ្ជូនទៅណាទេ មៅ៉ភ្នំពេញម្ដង ។

ដានី ៖ ភ្នំពេញអ្ហូស?

សំអុន ៖ បាទ ។

ដានី ៖ ពេលមកភ្នំពេញមកនៅកន្លែងណា?

សំអុន ៖ មកនៅខ្ញុំអត់ស្គាល់ទេ ពិនតែថាអត់ដែរចេញទៅណា គ្រាន់គេថាជិតពហុកីឡាដ្ឋានជាតិ អារអីស្ដាតចាស់ហ្នឹង កន្លែងហ្នឹងដូចជាកន្លែងគេបង់លុយបង់កាក់ផងតាមមើលពីដើមមក ។

ដានី ៖ កន្លែងស្ដាតអូឡាំពិច?

សំអុន ៖ បាទ!ស្ដាតអូឡាំពិច អាកន្លែងស្ដាតចាស់ហ្នឹង ដឹងនៅណាទេ ខ្ញុំអត់ដឹង ។

ដានី ៖ ចុះកន្លែងស្នាក់នៅគេហៅកន្លែងអីគេ?

សំអុន ៖ មិនដឹងអត់ដឹងដែរ ។

ដានី ៖ ចុះពូមុនពេលពូចេញទៅយើងមានដូចថា យើងមានចិនអីគេមកសំភាសន៍ឬក៏មានទិញ សំបុត្រអីកន្លែងអាកាសចរណ៍អីទេ?

សំអុន ៖ អត់!អត់ទាន់មានទេ ព្រោះចេះខ្ញុំសូមជំរាបជូនឲ្យបានច្បាស់តិច ពេលចេញដំណើរទៅស្រុកគេហ្នឹង ខ្ញុំទៅដល់ហ្នឹងសម្រាកកន្លែងហ្នឹងហើយកន្លែងដែលខ្ញុំមិនស្គាល់ ហ្នឹងគេថាជិតស្ដាតអូរឡាំពិចហ្នឹងស្នាក់ហ្នឹងហើយគឺនៅតែហ្នឹងហ្នងទៅគេមកវាស់ខោវាស់អាវ ផ្លាស់ប្ដូរខោអាវហើយណាស់ គេវាស់ខោវាស់អាវក៏វាស់នៅកន្លែងខ្ញុំហ្នឹងដែរ ហើយស្បែកជើងស្បែកអីហ្នឹងក៏គេផ្ដល់ឲ្យកន្លែងហ្នឹងដែរ ។ ហូបបាយតាកន្លែងជិតហ្នឹងទេ អត់មានទៅកន្លែងណាទៀត

អត់មានបានដើរទៅណាទេ ហើយក៏អត់មានឃើញអ្នកណាមកកន្លែងខ្ញុំដែរបាទ ។ អត់មានឃើញទេ ហើយក៏មិនគិតថាធ្វើវីសារថាអីណាអត់ដែរ អត់ដឹងទេ យើងអត់មានទាក់ទិនទេ ដឹងថារៀបចំខ្លួន ដល់ម៉ោងឡានគេមកដឹកទៅចំណតយន្តហោះហ្នឹង គាប៉ុណ្ណឹង ។

ដានី : អត់មានប៉ាសព័រទេ?

សំអុន : អត់មានទេ អត់មានអីទាំងអស់ គឺបញ្ជូនទៅ គាខ្លួនយើងអត់មានស្អីដែរ មានគារបស់អីដែលនៅខ្លួនយើងមានតែបិចមួយ កូនសៀវភៅមួយ នាឡិកាមួយប៉ុណ្ណឹងខ្ញុំ ហីខោអាវអត់មានដែរ ខោអាវនៅគេទាំងអស់ មានតែម៉ាចង្កេះន្រ្តះខ្លួនហ្នឹងទៅ ព្រោះយើងស្លៀកវានេះហើយហ្នឹងឡើងយន្តហោះទៅតែប៉ុណ្ណឹង ។

ដានី : ចុះមុនចេញទៅចិនអត់មានមកសំភាសន៍ អត់មានមកធ្វើប្រវត្តិរូបយើងអីទេ?

សំអុន : អត់មានទេ អត់មានទេ អត់មានថាមកដេញដោលអីទេ ទៅដល់ស្រុកគេនោះក៏អត់មានអីទៀតដែរ សារថ្មីពិនិត្យសុខភាពសារថ្មី ។

ដានី :ចុះពូកាលជិះយន្តហោះទៅ យន្តហោះរបស់ចិនឬក៏យន្តហោះរបស់ខ្មែរយើង?

សំអុន : យន្តហោះរបស់ចិន ។

ដានី : យន្តហោះម៉ាក់អីគេ កាលហ្នឹងយន្តហោះ?

សំអុន : កាលហ្នឹងគេហៅថាបូអិញ កាលហ្នឹងគេហៅថាស្អីណាខ្ញុំមិនបានមើលអីឃើញទាំងអស់ ។

ដានី : អត់ដឹង?

សំអុន : អត់ដឹង ដឹងថាម៉ាក់ស្អីជាម៉ាក់ស្អីទេ ។

ដារ៉ា : ពីណាដឹកនាំទៅពូ?

សំអុន : កាលដំបូងខ្ញុំដែលទៅ អ្នកដែលទៅឈ្មោះ ប៉ាវ គេប្រធានក្រុម ។

ដារ៉ា : ខ្មែរយើងទេ?

សំអុន : ខ្មែរអ្នកដឹកនាំទៅមានតាហ្នឹងទេ ហីទៅដល់លើយន្តហោះបានមានអ្នកបកប្រែអ្នកបកប្រែចិនបាននៅបកប្រែប្រាប់ ។

ដានី : យន្តហោះហ្នឹងជិះគ្នាបានប៉ុន្មាននាក់ដែលយើងទៅ?

សំអុន : យេ!មនុស្សវាច្រើនដែរ ពិនខ្ញុំជិះតាម៉ាក្រុមខ្ញុំឃើញតាម៉ាក្រុមខ្ញុំហ្នឹងទៅ វាច្រើនកង់ៗណាប្អូនច្រើនបន្ទប់ ។

ដានី : ចុះដូចថាថ្នាក់ដឹកនាំយើងជូន?

សំអុន : ឃើញទៅជូនទៅគឺអៀង សារី ។

ដានី ៖  អៀង សារី?

សំអុន ៖ គាត់ឡើងកប៉ាល់ហោះឡើងបានពាក់កណ្ដាលផ្លូវគាត់មក គាត់ចេញមកចាប់ដៃចាប់ជើងដែរ រាក់ទាក់ដែរ ហើយប្រាប់ថាខំប្រឹងរៀនសូត្រទៅ ព្រោះកន្លែងហ្នឹងគេធ្វើអី គេធ្វើតែក្រឡាចក្រត្រង់ដូចភ្លឺស្រែ ដូចភ្លឺស្រែក្រឡាចក្រត្រង់គេខំប្រឹងធ្វើនេះដែរ យើងខំប្រឹងរៀនសូត្រនោះទៅហីប៉ុណ្ណឹងទេ ។

ដានី ៖  កាលហ្នុងពូស្គាល់អៀង សារី ច្បាស់ដែរ?

សំអុន ៖ ស្គាល់ អត់ដែរស្គាល់ពីមុនដែរទើបតែស្គាល់ថ្ងៃហ្នឹង លឺតែឈ្មោះដែលពីមុន អត់ដែលឃើញនេះទេ តែស្គាល់ក្រោយមកឃើញតែរូបថតទេ ។

ដានី ៖  គាត់ប្រាប់ពេលនៅក្នុងយន្តហោះហ្នុងគាត់ប្រាប់ឈ្មោះគាត់ថា គាត់ឈ្មោះអៀង សារីចឹង?

សំអុន ៖ បាទ!គាត់អត់មានប្រាប់ខ្លួនគាត់ទេ ពិនគេប្រាប់ខ្ញុំ ។

ដានី ៖  គេប្រាប់?

សំអុន ៖ តាអៀង សារី ហៅតា តាអៀង សារី គាត់មៅ ចាប់ដៃចាប់ជើងហ្នឹង ចាប់ដៃយើងរាក់ទាក់ហ្នឹង ។

ដានី ៖  កាលហ្នុងដឹងថាគាត់ធ្វើ តួនាទីគាត់ធ្វើអីដែរ?

សំអុន ៖ ក្រសួងការបរទេស ។

ដានី ៖  ក្រសួងការបរទេស?

សំអុន ៖ បាទ ។

ដានី ៖  គាត់តែម្នាក់ឯង ឬក៏មានអ្នកផ្សេងៗទៀតអមទៅជាមួយដែរ?

សំអុន ៖ គាត់ចេញទៅពាក់អាវស ស្លៀកខោខ្មៅធម្មតាហ្នឹង ពិនណាតែម្នាក់ឯងទេ ជួបលើយន្តហោះហ្នឹង យើងក្រោកឈរឡើងចាប់ដៃគាត់រាក់ទាក់គាត់ធម្មតាចឹងទៅ ។

ដានី ៖  យន្តហោះហោះប៉ុន្មានម៉ោងពីភ្នំពេញទៅ?

សំអុន ៖ អេរ!កាលហ្នឹងដូចយូរ ខ្ញុំឡើងទៅតាំងម៉ោង១២ យន្តហោះហ្នឹងយូរមិនដូចអាឡូវទេ ខ្ញុំ ឡើងទៅម៉ោង១២គត់ ចេញទៅដល់នោះម៉ោង៥នាទ្បិកាយើងនេះ ពិនគេស្រែកប្រកាសដល់សៀងហៃគេក្រឡឹងចឹង គេប្រាប់ថាឲ្យសារ៉េម៉ោងឲ្យខុសគ្នាម៉ាម៉ោងយើងម៉ោង៥នេះគេម៉ោង៦នោះ ។

ដានី ៖  អញ្ចឹងយើងចេញពីភ្នំពេញទៅម៉ោង១២ថ្ងៃ?

សំអុន ៖ បាទ!ថ្ងៃ ។

ដានី ៖ អញ្ចឹងទៅដល់កន្លែងសៀងហៃហ្នឹងម៉ោង៩?

សំអុន ៖ បាទ!ល្ងាច ។

ដានី ៖ ម៉ោង៩ល្ងាច ប៉ុន្តែម៉ោងអត់ទាន់សាវ៉េ?

សំអុន ៖ ម៉ោង៦ ម៉ោង៩យើង ។

ដានី ៖ ម៉ោង៦សៀងហៃ?

សំអុន ៖ បាទ!ម៉ោង៦សៀងហៃ ទៅដល់គេប្រកាសឲ្យយើងសាវ៉េម៉ោងដូចថានាឡិកាតំបន់គេហ្នឹង ។

ដារ៉ា ៖ ចុះអ្នកនាំទៅពេលឡើងយន្តហោះនោះ ដែលពូថាពេលដល់ឡើងយន្តហោះមានអ្នកបកប្រែ?

សំអុន ៖ បាទៗ ។

ដារ៉ា ៖ ចឹងអ្នកណាអ្នកបកប្រែឈ្មោះអី?

សំអុន ៖ ចិន អត់ស្គាល់ឈ្មោះគេទេ ។

ដានី ៖ ខ្មែរហើយហីចិន?

សំអុន ៖ មិនដឹងខ្មែរហីចិន គេនិយាយខ្មែរច្បាស់ដែរពិនថាចេះ ខ្ញុំសូមជំរាបរឿងអ្នកបកប្រែខ្មែរ-ចិនហ្នឹងពីមុនចិនឲ្យមនុស្សមកនៅស្រុកខ្មែរយូរហើយ ជាកូនចៅ ដូចកូនចៅចិននៅស្រុកខ្មែរហើយ ចឹងរៀនអក្សរសាស្ត្ររៀនអី អ្នកខ្លះមានបួសទៀតបាទ!ខ្ញុំដល់នោះបានខ្ញុំដឹង គាត់បួស គ្រាន់តែនិយាយភាសាមួយជាភាសាហ្នឹងចូលមើលក្នុងរោងកុនទេ គាត់អង្គុយជិតខ្ញុំ ហើយគាត់និយាយពីដែលថា សួរខ្ញុំអាយុប៉ុន្មាន?ខ្ញុំប្រាប់អាយុគាត់ ហីខ្ញុំសុំទោសគាត់ណា គាត់អាយុប៉ុន្មានដែរ?គាត់ថាគាត់សែសិបដ្ឋាយហើយ ។ ខ្ញុំថាអាដ្ឋាយនេះកម្ររអ្នកចេះនិយាយណាស់ បានខ្ញុំឆ្ងល់ណាស់ថាលោកគ្រូម៉េចចេះប្រើពាក្យភាសានៅស្រុកខ្មែរ ។ គាត់ថា ហ៊ីខ្ញុំបួសនៅស្រុកខ្មែរបាលីទៀត គាត់បួសដែរហើយ បួសអាចារ្យបាលីប្រហែលគ្នាដែរ ដូច្នេះឈ្មោះអ្នកដែលបកប្រែកន្លែងខ្ញុំចិននោះឈ្មោះ យឹម សូហ្វា គាត់រកស៊ីតាស្រុកចិនហ្នឹង គ្រូគាត់ឈ្មោះ សុន សេន យើង សុន សេន ខ្មែរក្រហមយើងបាញ់នេះហ្នឹងណា សុន សេនហ្នឹងជាគ្រូបង្រៀនគាត់ពីមុន បង្រៀនភាសាខ្មែរហ្នឹង ពិនកាចណាស់វ៉ៃគាត់ គាត់ថាចឹង គាត់ទៅនិយាយប្រាប់ខ្ញុំថា កាចណាស់តាហ្នឹង វ៉ៃឲ្យគេរៀនខ្មែរ គាត់នៅស្រុកខ្មែរយូរហើយ ឃុំគាត់នៅហ្នឹងអី ហ្នឹងគាត់នៅ ហើយគាត់និយាយច្បាស់ថែសខ្មែរសុទ្ធ ពិនតែគេជនជាតិចិនគាត់ប្រាប់រឿងរ៉ាវគាត់មិនអស់ ។

ដារ៉ា ៖ ឈ្មោះគាត់ឈ្មោះអីគេ?

សំអុន ៖ ឈ្មោះ យឹម សូហ្វា ។

ដានី ៖  យឺម សូហ្វា?

សំអុន ៖ បាទ!គាត់ចាស់ហើយអាឡូវហ្នឹង ។

ដានី ៖  ចុះពូក្រុមពូទៅ ពូមាននាឡិកាមានអីគ្រប់គ្នាចឹងហ្មង?

សំអុន ៖ មានទៅដល់នោះគេដកបាត់ ដកហើយ គេដកចេញអស់រលីញ គេទិញថ្មីយកមកឲ្យមួយទៀតយកអាមួលឡានមួង កាលខ្ញុំចេញទៅខ្ញុំពាក់តិចណូសក្រហមគួក្រហម ។

ដានី ៖  ឈ្មោះអីគេ?

សំអុន ៖ តិចណូស នាឡិកាតិចណូស ។

ដានី ៖  តិចណូស?

សំអុន ៖ បាទ ។

ដានី ៖  ចឹងពូក្រុមយើងទៅទាំង៨៥នាក់ហ្នឹងយើងមាននាឡិកាខ្លួនឯងឬអង្គការទិញឲ្យ?

សំអុន ៖ ពីមុនមានខ្លួនឯង ដល់តែយកអាខ្លួនឯងហ្មងចេញទៅ គេទិញអារបស់ស្រុកចិនម៉ោ គេដាក់ឈ្មោះអីគេ ឈ្មោះឈុនលៃ ឈុនលៃ ភាសាចិនឈុនលៃ ហ្នឹងគេឲ្យយើងពាក់មួលឡានពាក់ទៅ ហើយចិនៗទូទៅភាគច្រើនមួលឡានហ្មងឯង ចិនក៏ពាក់មួលឡានដែរ ។

ដានី ៖  ចុះពូយ៉ាងម៉េចទៀតទៅពេលដែលយន្តហោះចុះដល់សៀងហៃហ្នឹងហើយ យ៉ាងម៉េចយើង?

សំអុន ៖ អត់មានអីទេ ឡានគេមកទទួលយើងទៅ យើងដល់កន្លែងសម្រាក កន្លែងអីខាង កន្លែងហ្មង ខ្ញុំនៅជាមួយដើងទឹកដែរ ។ តំបន់កន្លែងដើងទឹកហ្នឹង កន្លែងដើងទឹកហ្នឹង ព្រលឹមឡើង បានខ្ញុំជួបព្រោះយប់ឡើងហ្នឹងគេធ្វើគោ ធ្វើអីជប់លៀងហូបចុក ហូបអីហើយហ្នឹងអូនដល់ ព្រលឹមហើយទើបខ្ញុំឃើញមាន តាគីចាង បាគីស្ថាន សាអៀរ នៅជាប់ហ្នឹងដែរ មានអគារវា បីជាន់បីជាន់ហ្នឹងមានបីអាគារធំៗ ។

ដានី ៖  មានបាគីស្ថាន?

សំអុន ៖ បាគីស្ថាន សាអៀរ សាអៀរនៅ ប្រទេសសាអៀរជាប់កុងហ្គោមើលដែនទីដឹង ។

ដានី ៖  មានតែពីរហ្នឹងទេ?

សំអុន ៖ បាទ!កាលហ្នឹងទៅឃើញមានតែពីរហ្នឹង ពីរហ្នឹងចូលហីក្រោយមកទៀតមានកាមារ៉ូន មានអីនៅហ្នឹង មានតង់ដានី គេទៅនៅហ្នឹង គេខាងដើងទឹក ពួកអាខេងនៅជាប់ៗសមុទ្រហ្នឹងវាមានហើយ ។

ដានី ៖  ឈ្មោះអីគេកន្លែងដែលពូនៅហ្នឹង គេដាក់ឈ្មោះថាម៉េចទៅ?

សំអុន ៖ ខ្ញុំអាកន្លែងហ្នឹងគេហៅថា អូសុង អូសុងកន្លែងទ័ពដើងទឹកគេ ខាងទ័ពដើងទឹក ។

ដានី ៖ ខាងទ័ពដើងទឹក?

សំអុន ៖ បាទ!តែខ្ញុំអត់មានឃើញកន្លែងទ័ព កន្លែងអីទៀតទេគ្រាន់តែឃើញទ័ពគេយាម ។

ដានី ៖ ភាសាចិនវូសុងហ្នឹង ទ័ពជើងទឹក?

សំអុន ៖ អត់មានទេ អូសុងជាតំបន់គេ ។

ដានី ៖ តំបន់អ្ហេស?

សំអុន ៖ ដូចថា ភ្នំខណ្ឌចំការមន អីចឹងទៅណា ខណ្ឌមានជ័យអីចឹងទៅណា ។

ដានី ៖ អីគេ? អូ? ។

សំអុន ៖ អូសុង បាទ ។

ដានី ៖ តែកន្លែងហ្នឹងកន្លែងទ័ពជើងទឹក?

សំអុន ៖ បាទ!កន្លែងទ័ពជើងទឹក ។

ដានី ៖ ទ័ពជើងទឹករបស់ សៀង ហៃ ឬក៏របស់ប្រទេសចិនហ្នុង?

សំអុន ៖ ទ័ពសៀងហៃ ហ្នឹង ពិនតែទ័ពៗរបស់គេទាំងអស់ ទ័ពចិនទាំងអស់ហ្នឹងទ័ពចិនទាំងអស់ ប៉ុន្តែគេជាកន្លែងសម្រាប់ហ្វឹកហ្វឺន ពួកអន្តរជាតិគេដែលនៅហ្នឹង ទទួលអន្តរជាតិ មូលដ្ឋានទ័ព គេដែលធំដុំមិនដឹងជានៅកន្លែងណាទេឃើញទ័ពជើងទឹក ឃើញស្ទៀកពាក់ជើងទឹកទាំងអស់ ហ្នឹងគេមកយាមមកកាមអីកន្លែងហ្នឹង ។

ដានី ៖ ទៅដល់ដំបូងគេឲ្យយើងធ្វើអីខ្លះទៅ?

សំអុន ៖ ដំបូងរៀនភាសាចូលសាលាភាសា បានហ្វឹកហ្វឺនភាសា តែអភ័ព្វខ្ញុំណាស់ ខ្ញុំទៅដល់ពិនិត្យសុខភាពហើយ ពេទ្យថាខ្ញុំមានជម្ងឺថ្លើម ដូច្នេះខ្ញុំត្រូវគេបញ្ជូនមកពេទ្យហុងឆរអ៊ីយ័ន ហុងឆរអ៊ីយ័ន ហ្នឹងគេហៅថាកន្លែងមន្ទីរពេទ្យទង់ក្រហមគេហ្នឹងបាទ!នៅហ្នឹងពខែខ្ញុំនៅក្នុង នោះក៏ខ្ញុំឆ្លៀតទៅរៀនភាសាគេដែរ ។ ចេញមកវិញបានរៀនក្នុងសាលាជាមួយគេបាន៣ខែទៀតទើបចេញទៅរោងចក្រសាំងរោងចក្រគេនោះ ។

ដារ៉ា ៖ រៀន៤ឆ្នាំអ្ហី? ៧៦ដល់៨១ ៥ឆ្នាំ?

សំអុន ៖ ៤ឆ្នាំជាងទេ បើគិតតាមតួលេខ បើសងវា៥ បើគិតជាសាច់ការប្រហែល៤ឆ្នាំជាង ។

ដារ៉ា ៖ តែរៀបបច្ចេកទេសច្រើនអ្ហេស?

សំអុន ៖ បាទ!ខ្ញុំរៀនផ្នែកអាស៊ីតិចអស់ហើយ ខ្ញុំរៀនបើខ្ញុំរៀនដាក់ស្ដែងតិចណាស់ ដាក់ស្ដែងតាថ្ងៃសុក្រថ្ងៃសៅរ៍ ចឹងហើយថ្ងៃសុក្រថ្ងៃសៅរ៍សម្រាកថ្ងៃអាទិត្យថ្ងៃព្រហស្បតិ៍ថ្ងៃសុក្រ បានសៅរ៍ថ្ងៃអាទិត្យសម្រាក២ថ្ងៃ ក្រៅថ្ងៃ៣ថ្ងៃហ្នឹង ខ្ញុំរៀនសាលារៀន សាលាហ្នឹងជាគូរបន្ទំផង

ទ្រឹស្ដីផង ។ ហីហ្នឹងរៀនខាងគណិតសាស្ត្រ កាលហ្នឹងខ្ញុំរៀនដល់គណិតសាស្ត្រវាខ្ពស់ដែរ ភ្លេចអស់ហើយ លូការីទ អាំងតេក្រាល់អីដូចតាយើងចឹងថ្នាក់ខ្ពស់ៗណាស់ ច្រើនណាស់ ព្រោះលេខនៅកន្លែងហ្នឹងយើងពិបាកប្រាប់ណាស់ ព្រោះវាគិតតាំងពីកម្លាំង ចុះកប៉ាល់យើងធ្វើអាខេញកប៉ាល់ហ្នឹងយើងធ្វើគួសំខាន់ជាងគេ ព្រោះកប៉ាល់ហ្នឹងយើងធ្វើមិនស្រួលយើងអត់លឿន ។ ធ្វើនេះទៅវាជ្រៅពេក ស៊ីទឹកខ្លាំងពេក វាស្ទះទឹកដូច្នេះយើងគិតអំពីកម្លាំងអាខេងដែលគេហៅអីកម្លាំងនៅក្នុងលំហរអាកាសកម្លាំងក្នុងលំហរ កម្លាំងនៅចឹងកម្លាំងនៅកន្លែងណាគេសួរ កម្លាំងខ្ពស់ពេកវាពែលប៉ោល ទាបពេកវាស៊ីទឹកជ្រៅបានស៊ីទឹក ជ្រៅពេកដូច្នេះយើងគិតតាមហ្នឹងដែរ ។ គិតតាមវាហើយលើខ្លួននាវាក្រឡាផ្ទៃក្រឡាអីហ្នឹង គិតអាបេះយើងគិតអាម៉េចកើតមានចតុកោណកែងមានចតុកោណស្មើរអីកើតដូចគេ ដល់តែប្រើអាំងតេក្រាល់ ។

ដាភី ៖ កាលហ្នុងពូថាពូរៀនសូត្របានត្រឹមថ្នាក់ទី៧ ពីសង្គមហ្នឹង?

សំអុន ៖ បាទ ។

ដាភី ៖ បើនិយាយទៅបើធៀបពីអាឡូវថ្នាក់ទីប៉ុន្មាន?

សំអុន ៖ មិនដឹងទេ ។

ដានី ៖ ទី៧ ដដែលហ្នឹងប្រហែលទី៧ រៀនបាន៧ឆ្នាំពូ?

សំអុន ៖ ទី៧ ៦៤បាទ ។

ដាភី ៖ ឌីប្លូម ពូ?

សំអុន ៖ បាទៗ ។

ដាភី ៖ ពូឯងប្រលងឌីប្លូមនៅ?

សំអុន ៖ កាលហ្នឹងឌីប្លូមនៅទេ ឌីប្លូមឆ្នាំគេរាប់តាំងពីទី១២ម៉ោ ១២-១១-១០-១២អ្ហាស១២ ១០ចឹងអ្ហេស ។

ដានី ៖ ១២-១១?

សំអុន ៖ អើរ ១២-១១-១០-៩-៨-៧-៦ឆ្នាំខ្ញុំ៦ឆ្នាំ ។

ដាភី ៖ ៦ឆ្នាំ បើធៀបមកអាឡូវកេលេសហ្នឹង?

សំអុន ៖ បាទ ។

ដាភី ៖ បឋមសិក្សាហ្នឹង?

សំអុន ៖ អាហ្នឹងបឋមហ្នឹង តែបឋមបើគិតទៅនៅនោះបឋមទេ ព្រោះឆ្លងពីបឋមមកថ្នាក់ទី៣ ដឹនាន់ខ្ញុំថ្នាក់ទី៣ ប្រលងឌីប្លូម ប្រលងឌីប្លូមហ្នឹងបាន បានប្រលងគ្រូបាន ។

ដារ៉ា ៖ ចឹងនៅបឋម ប៉ុន្តែដល់ពេលទៅដល់ចិនម៉េចក៏រៀនបានទៅកើត?

សំអុន ៖ បាទ!កាលបួសខ្ញុំរៀបបន្តទៀត នៅបួស បួសខ្ញុំបន្តរៀនទៀត បួសរៀនដូចជាយើងចឹងដែរ ដូចជារៀនយើងនៅក្នុងចឹង បួសរៀនភាសាបាលី ។ ភាសាបាលីហ្នឹងមិនដូចរៀនធម្មធម្ម រៀនតែធម៌ព្រះពុទ្ធហ្នុង នៅនោះធម៌ព្រះពុទ្ធគេរៀនតែម៉ាឆ្នាំ ខាងខ្ញុំម៉ាឆ្នាំគេរៀនវេយ្យាករណ៍ វេយ្យាករណ៍ដើម្បីប្រែគម្ពីរ ចាប់ផ្ដើមប្រែគម្ពីរ៨ក្បាល ធម្មបទ៨ក្បាលហ្នឹងទៅ បានប្រែគម្ពីរហ្នឹងហើយបានយើងយកទៅប្រលងវង ប្រលងវងយកសញ្ញាបត្រចូលនេះដែរ ។ ហីចឹងនៅក្នុងលោកសង្ឃហ្នឹងគេរៀនដូចចឹង ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ប្រវត្តិវិទ្យា ភូមិវិទ្យាដូចគ្នា មានគ្រប់យ៉ាងដូចកូនសិស្សចឹងដែរ ។ គ្រាន់តែប្លែកគ្នាគ្រាន់ថាមួយគេរៀនភាសាបរទេស មួយគេរៀនបកប្រែបាលីគម្ពីរ ។ បានតែខ្ញុំក៏ឆ្លៀតរៀនម៉ាម៉ោង១ដែរ ក្នុងម៉ាអាទិត្យ គ្រូគេបង្រៀនខាងភាសាដែរ ។

ដានី ៖ ចុះពូដូច ពូមានប្រសាសន៍មិញ ពូបានរៀនច្រើន បួសហើយបានរៀនទៀត ចុះអ្នកផ្សេងទៀត? ៤៥នាក់នោះពូ?

សំអុន ៖ អូរ!ពួកនាក់៤៥ ទៅមួយខ្ញុំ? អ្នកខ្លះអត់ចេះអក្សរទេ ខ្ញុំទៅដល់នោះខ្ញុំវេទនាណាស់ គឺខ្ញុំហ្នឹងហ្នុង ខ្ញុំមិនថាអួតខ្លួនទេលោកតែខ្ញុំវេទនា ពីថ្ងៃរៀនជាមួយគ្នាយប់ឡើងខ្ញុំមកបង្រៀន គេទៀតហើយរៀនខ្លួនឯងទៀតវាចេះ ហីគេក៏វាតឹងតែងហើយប្រធានហ្នឹងហាក់ដូចជាមិន សូវពេញចិត្តខ្ញុំដែរ ។ ខ្ញុំពិបាកពេកហីគេចេះដែរ ចេះដូចគ្នាណាស់អ្នកខ្លះគ្រាន់តែមើលអក្សរដៃអ្នកខ្លះងត់ចេះសោះ អត់ចេះសោះអក្សរខ្មែរ ចិនគ្រវីក្បាលដែរ ខ្ញុំនិយាយប្រាប់ត្រង់ទៅចិនគ្រវីក្បាលថាប្រើមនុស្សមិនចេះអីសោះម៉ោស្រុកគេ ខ្ញុំដឹងកាលហ្នឹង ហីគេវាអីចេះដែរ វាផ្ដាច់ការទាក់ទង ព្រោះយើងខ្ញុំអាសារនិយាយជាមួយចិនណាស់ ទំនាក់ទំនងគ្នា មួយបាគីស្ថានអីខ្ញុំអាសារនិយាយណាស់ និយាយលេងគេអត់ឲ្យនិយាយទេ ហាមអត់ឲ្យជួបទេ ប្រាប់ពេលប្រជុំគេតិះទៀនយើងដែរ ។ រិះគន់ហើយកុំឲ្យមិនត្រូវទាក់ទងមួយបរទេស ទោះបីតែចិនហ្នឹងដែលយើងនៅស្រុកគេហើយហ្នឹងខ្ញុំនិយាយមួយចិន ចិនថាគួរតែល្អ ខំប្រឹងរៀនភាសាចឹងខំប្រឹងហាត់និយាយចឹង យើងហាត់និយាយសន្ទនាគ្នាទៅវិញទៅ ម៉ោយើងឆាប់ចេះឆាប់យល់តែចំនែកមេខ្ញុំនេះមិនឲ្យទាក់ទងទេ ។

ដារ៉ា ៖ ឈ្មោះអីមេហ្នឹង?

សំអុន ៖ ឈ្មោះ ប៉ាវ ។

ដានី ៖ តាប៉ាវ?

សំអុន ៖ បាទ!កាលមុនឋានៈគេកងវរៈ ប្រធានវរសេនាតូច ដល់នោះគ្នាប់ជាមេក្រុមរបស់ពួកខ្ញុំពួកអ្នកបច្ចេកទេសហ្នឹងតឹងតែងណាស់ ខ្ញុំនៅនោះខ្ញុំថា ពិនយ៉ាងណាខ្ញុំនៅតែធ្វើចឹង ខ្ញុំនៅតែនិយាយចិនក៏នៅមកសួរខ្ញុំចឹងទៅ ខ្ញុំក៏និយាយទៅ ហើយបើខ្ញុំនិយាយតិះទៀនខ្ញុំ ខ្ញុំនិយាយម៉េចកើត បើគេសួរខ្ញុំ ខ្ញុំមិនឆ្លើយនឹងគេ ខ្ញុំមិនឈ្លើយ បានចឹងខ្ញុំនិយាយតបទៅចិន វិញវាស្ងាត់មាត់ដែរ ។ ហើយចឹងបានគេមិនសូវចូលចិត្តខ្ញុំទេ ពួកអស់នោះអាណាវៀនពូកែជាងគេមិនបានទេ កាលជំនាន់ហ្នឹង ជំនាន់ខ្ញុំអាក្រុមខ្ញុំហ្នឹងហ្នង អាក្រៅពីហ្នឹងខ្ញុំអត់ដឹងទេ ខ្ញុំខឹងណាស់ ខ្ញុំឈឺចាប់ទល់អាឡូវហ្នឹង រិះគន់ខ្ញុំមាំណាស់ ពិនតែខ្ញុំនៅតែគ្មានទេ ព្រោះខ្ញុំមេលើប្រាប់ចឹងខំប្រឹងរៀនសូត្រអត់មានទេ បើអញ្ចឹងខ្ញុំផាប់បាត់ហើយ អាហ្នឹងបើសិនបើមេខ្ញុំម៉ោនៅកាលខ្ញុំនៅនេះតែវាម៉ោមុនខ្ញុំទៀត ។

ដារ៉ា ៖ ណាគេ ឈ្មោះ ប៉ាវ?

សំអុន ៖ បាទ!មកមុនខ្ញុំ ។

ដានី ៖ មកឆ្នាំណា?

សំអុន ៖ មកឆ្នាំប៉ុន្មានទេ មក៨០ មក៧៩ ម៉ាសារបានគេត្រឡប់ទៅវិញម៉ាសារ គេទៅពីរដង ។

ដានី ៖ តាប៉ាវ ទៅនៅស្រុកណាដែរ?

សំអុន ៖ អត់ស្គាល់ទេ ខ្ញុំមិនដែលសួរនាំ ។

ដានី ៖ ចុះពូ ពូទៅរៀនភាសាតែ៦ខែ ចុះពីមុនមកយើងអត់ចេះអីសោះ៦ខែយើងចូលទៅសាលាយើងរៀនម៉េចទាន់គេទៅ?

សំអុន ៖ ៦ខែអូរខ្ញុំរៀន៣ខែ ខ្ញុំនៅនេះអ្នកបកប្រែមកបង្រៀនខ្ញុំនៅនេះដែរ តែគេអត់ឲ្យរៀន ខ្លាំងទេណា នៅមន្ទីរពេទ្យចុះមានអីយើងរៀនយើងចេះតែប្រឹងរៀនទៅ ប្រឹងរៀនដូចភាសា ដទៃដូចអង់គ្លេសដូចបារាំងចឹងខ្ញុំធ្លាប់ស្គាល់គេតិចតួចគេមានបកប្រែបកអីក្នុងសៀវភៅ ចឹងទៅណាស់គ្រាន់តែអានយើងមិនចេះអាន ជួនកាលយើងសួរពេទ្យ យកថ្នាំមកឲ្យយើងលេប មកចាក់ថ្នាំយើងសួរថាអក្សរនេះអានថាម៉េច ។ ស្គាល់ម៉ាម៉ាត់ពីរម៉ាត់យើងចេះតាសួរទៅ ម៉ាម៉ាត់ពីរម៉ាត់យើងចេះតែសួរ សួរបណ្តើរៗយើងចេះតាចងចាំរបស់យើងបណ្តើរៗទៅ បើយើងមិនសង្ងាត់ចឹងយើងមិនទាន់គេទេ ហើយអាគេអ្នកអត់សង្ងាត់នៅតាបកប្រែឲ្យវាចឹង ខ្មែរបកប្រែឲ្យខ្មែរទៅ ។

ដានី ៖ បានន័យថានៅក្នុងថ្នាក់ហ្នឹងរៀនខ្មែរយើងសុទ្ធ ហើយគ្រូចិនគេមៅបង្រៀនឬក៏មានចំរុះជនជាតិ?

សំអុន ៖ អត់មានចំរុះទេ គឺយើងជាខ្មែរសុទ្ធ ហើយមានគ្រូចិនគេម៉ោបង្រៀនយើង ហើយមានអ្នកបកប្រែម្នាក់ចាំជួយបកប្រែ បកប្រែហ្នឹងម៉ាថ្នាក់ គេគិតថា២៥នាក់ ២៥ហ្នឹងឆ្លាស់គ្នា ចឹងទៅហីអ្នកបកប្រែក៏មិនជាច្រើនដែរ ។ គ្នារត់ពីថ្នាក់នេះផងទៅថ្នាក់នោះផងចឹងទៅ ឲ្យតែយើងហាត់អានតាមគ្រូសិនទៅ ហើយយើងឲ្យសញ្ញាដែលយើងធ្លាប់ចំណាំយូរៗទៅយើងចេះ តែដឹងចឹងយើងមិនបាច់ចាំទល់តែអ្នកបកប្រែមកផ្ទាល់បានយើងធ្វើកើតទេ ។ អាចគ្រូថាឲ្យថាតាមយើងដឹងថាពាក្យគាត់ឲ្យថាតាមថាម៉េច យើងដឹងថាតាមគាត់ចឹងទៅ ឲ្យសរសេរ សេរម៉េច យើងសរសេរ យូរទៅយើងអាចនិយាយគ្នាដោយកាយវិការបាន បានហីដល់យើងចេះបកប្រែបកអីទៅ យើងបានស្គាល់ពីក្នុងសាលាដូច៦ខែ វាគួរសមហើយ ល្មមប្រើប្រាស់បានយើងទៅនិយាយជាមួយកម្មករនៅរោងចក្រហ្នុង រោងចក្រយើងបន្ថែមហ្នឹងទៀតយើងនិយាយទៅ អត់មានអ្នកបកប្រែតាមយើងទេ ពេលហ្នឹងយើងថាស្អីៗ ហ្នឹងយើងចង់រកដែក រកអាញ្ជូរ រកកាំបិត ពូថៅអី របស់របរឧបករណ៍អីទាំងឡាយក្នុងរោងចក្រហ្នឹង យើងអាចសួរគេបាន ហើយយើងសន្ទនាគ្នា ទៅដល់ហ្នុងឲ្យតែយើងសំភី គឺយើងជឿនលឿនហើយហីបើយើងថាល្ងង់ពីដើមហើយប្រហែលជាលំបាកដែរ ។

ដារ៉ា ៖ ចំណោម៤៥នាក់ ទៅមួយពូហ្នឹងមានប៉ុន្មាននាក់ដែលរៀនពូកែជាងគេ?

សំអុន ៖ នេះប្រហែលជាក្នុង ៤៥នាក់ខ្ញុំថា ១០នាក់ជាងចុះ រាប់មិនអស់ទេ ភ្លេចគ្នាអស់ហើយ កន្លងម៉ោយូរហើយ១០នាក់ជាង ព្រោះមានគីម វាវហ្នឹងមួយ ប៉ាវហ្នឹងគេក៏រៀនខ្ពស់ដែរ ពីមុនមកគេមិនដែលបួសដែលអីទេ គីម ផុន នេះមួយ ។

ដានី ៖ ឈ្មោះអី?

សំអុន ៖ គីម ផុន ។

ដានី ៖ គីម ផុន?

សំអុន ៖ គីម ផុន ហ្នឹងក៏រៀនគួរសម ពូកែដែរ ។

ដានី ៖ អាឡូវគាត់នៅណា?

សំអុន ៖ បែងចែកផ្លូវគ្នា អត់ដឹងគេទៅណាទៅណីទេ បែកគ្នាអស់ហើយ កាលហ្នឹងគេចែកគ្នា ខ្ញុំខាងតួនាវា គេគីម ផុន ខាងអគ្គីសនី ប៉ាវ ហ្នឹងគេក្តាប់រូម វាខុសគ្នា ហើយមានខាងម៉ាស៊ីនខ្លះខាងម៉ាស៊ីចេះខ្លះ អាហ្នឹងដឹងតាម៉ាស៊ីនទេ ហើយក្រៅពីហ្នឹងយ៉ាប់ដែរ ។

ដារ៉ា ៖ ចុះអ្នកអត់បេះ អត់អី ម៉ោវិញអន្តការមិនរករឿងគាត់ហើយ?

សំអុន ៖ អត់ដឹង គេម៉ោវិញធ្វើអីផង គេម៉ោវិញអស់ហើយ បែកគ្នាអស់ហើយ ។

ដារ៉ា ៖ មកនៅឆ្នាំ៨១ ទាំងអស់គ្នាឬក៏ម៉េច?

សំអុន ៖ បាទ!អត់ទេ ខ្ញុំបែកពីគេ ខ្ញុំមកនៅឃុនទីញ ទៀត មកនៅឃុនទីញ ហ្នឹងប្រហែលជា ១ខែ ជាងទៅ បែកគ្នាអស់ហើយ ដឹងគេទៅណាទៅណីទេ ព្រោះគេនៅក្រោយខ្ញុំឬមុនខ្ញុំ ខ្ញុំអត់ដឹងទេ ហីខ្ញុំម៉ោ ឃុនទីញ ហ្នឹងម៉ោបេះ ខ្ញុំដូចបញ្ញើរ ព្រោះខ្ញុំមិនត្រូវគ្នាជាមួយ គឹម ប៉ាវ ហ្នឹងចឹងប្រធានហ្នឹងគេរៀបឲ្យខ្ញុំម៉ោនៅឃុនទីញប៉ុន្មាននាក់នោះម៉ោប្រហែលជា១០នាក់ជាង ។ អ្នកដែលនេះហ្នឹងគេបញ្ជូនម៉ោហ្នឹង មកនៅឃុនទីញហ្នឹងផ្ញើរខ្លួនមួយ ពួកកងទ័ពដែលគេយកទៅហ៊ឹកហ៊ឺននៅឃុនទីញហ្នឹងណា ។ កងទ័ពហ្នឹងតូចៗទេ ក្មេងៗខ្ញុំហ៊ឹកហ៊ឺនហ្នឹង ផ្ញើរគេហ្នឹង ដល់ពេលមកជាមួយគេមក ម៉ោមួយគេនៅស្រុកខ្មែរហ្នឹងចុះនៅថៃ ហ្នឹងហើយម៉ោ ឡើងម៉ោនេះម៉ោនៅព្រំដែនហ្នឹងម៉ោ ព្រំដែនហ្នឹងបានមេខ្ញុំទៅពីនេះទៅឈ្មោះ ទិន សេង នេះស្គាល់ ។ ទិន សេង ហ្នឹងគាត់នៅប្រធានកងពលទី៣ ហ្នឹងមាស មុត គាត់ទៅនៅឯជើងបាត់ហើយ កងពលទី៣ហ្នឹងគាត់ទៅយកខ្ញុំមកនៅកន្លែងគាត់ហើយអ្នកក្រៅពីហ្នឹងគេឲ្យម៉ោកាំភ្លើងធំ តែខ្ញុំមួយគាត់ទុកនៅកន្លែងគាត់តែម្ដង ។ ដូច្នេះខ្ញុំអត់ដែលកាន់កាំភ្លើងកាន់អីនឹងគេទេ ធ្វើអីក៏ដោយកាលនៅហ្នឹងគាត់ឲ្យខ្ញុំធ្វើគ្រូគេ បង្រៀនហ្នឹងទៅបង្រៀនបណ្ដុះបណ្ដាលគ្រូបន្ថែមទៀត ទៅឯងជាកំរិតម៉ាស្ទ័រទៅជានាយកសាលាហ្នឹងទៅធ្វើរហូតចឹងម៉ោ ។

ដារ៉ា ៖ ៨១ហ្នឹង?

សំអុន ៖ បាទ!៨១រហូតមកហ្នឹង ។

ដារ៉ា ៖ មកនៅម្ដុំណា៨១?

សំអុន ៖ ថ្មដា ថ្មដាលើត្រាចតិច ។

ដានី ៖ កាលពូទៅរៀននៅហ្នឹង កាលហ្នឹងពូរៀននៅសាលាភាសាផ្សេង តែពូទៅរៀនដាក់ស្ដែងយើងរៀននៅក្នុងរោងចក្រហ្នង?

សំអុន ៖ បាទ!រោងចក្រ បាទ!យើងទៅធ្វើការហ្នុង ធ្វើការក្នុងរោងចក្រណា បានព្រលឹមឡើងគេដឹកយើងទៅហើយ ។

ដានី ៖ ធ្វើកប៉ាល់?

សំអុន ៖ បាទ!អត់ទេ ធ្វើកប៉ាល់ហ្នឹងទៅរោងចក្រហ្នឹងគេហៅសូវ៉ាលីម៉ូ៨៨០៥ រោងចក្រអត់មានឈ្មោះទេ គេដាក់លេខរោងចក្រ៨៨០៥ ហ្នឹងជារោងចក្រសម្រាប់ជួសជុលនាវារបស់យោធា បាទ!សុទ្ធតែនាវាមុជទឹក ដឹករថក្រោះ បោះមីន ប្រដេញ ប្រឆាំង ។

ដានី ៖ បានន័យថាយើងទៅរៀនដាក់ស្ដែងក្នុងរោងចក្រហ្នឹង ធ្វើម៉េច យើងបង្រៀនរៀនហ្មង?

សំអុន ៖ បាទៗ!ធ្វើម៉េចរៀនចឹង រៀនអាហ្នឹងយើងទៅរៀនផ្សារ រៀនមើលរបៀបអាខូច ខាតអីហ្នឹងយ៉ាងម៉េចៗធ្វើយ៉ាងម៉េច តវ៉ា តក្បាលម៉េច វាបុកទៅបែក ទៅយើងតក្បាលម៉េចអីម៉េចតក្បាលកប៉ាលហ្នឹងមុខកប៉ាល់ហ្នឹង យើងរៀនតាមមុខសញ្ញារបស់យើង ហើយរៀននៅហ្នឹងហើយដាក់ស្ដែងពីរថ្ងៃ ថ្ងៃព្រហស្បតិ៍ថ្ងៃសុក្រចឹងទៅ ហើយក្រោយពីថ្ងៃហ្នឹងយើងមករៀនគូរប្លង់ គូរប្លង់ខុបមាថា ចង់ជួសជុលតែយើងចេះប្លង់ទៀត ។ ប្លង់ជញ្ជាំងនេះ ជញ្ជាំងនោះបាតក្រោម បាតលើ កន្លែងដាក់ម៉ាស៊ីនដាក់អីធ្វើ ដូចយើងធ្វើផ្ទះទុកឲ្យគេចឹងណា តួនាវាពិបាកដែរឲ្យគេដាក់ម៉ាស៊ីនកន្លែងណាដែលមិនបះតួខ មិនបះក្បាល ចឹងឥវ៉ែឥវ៉ាន់អីហ្នឹងយើងរៀបចំកន្លែងទុកឲ្យគេសម្រាប់តួហ្នឹង ហើយគេម៉ាស៊ីន គេដឹងតែយកមកដល់ដាក់ផ្ទឹប ។

ដានី ៖ កាលហ្នឹងពូខាងផ្នែកពូតែម្នាក់ពូទេ?

សំអុន ៖ អត់!ខ្ញុំម្នាក់ទេ ខ្ញុំពីរនាក់ ឈ្មោះ ជុំ វ៉ន មួយទៀតបាទ ។

ដាវ៉ា ៖ អាចជាសញ្ញាប័ត្រវិស្វករអត់?

សំអុន ៖ ទេ កាលហ្នឹងខ្ញុំមិនគិតដល់ហ្នឹងទេ ។

ដានី ៖ គេមានឲ្យសញ្ញាប័ត្រទេ ពេលរៀនចប់?

សំអុន ៖ អត់ទេ អត់មានទេស្រុកគេហ្នឹង អត់ចិនគេអាចមាន ខ្មែរយើងវាមិនដែលឲ្យសញ្ញាប័ត្រ ។

ដានី ៖ គេអត់ឲ្យទេចឹង?

សំអុន ៖ អត់អោយទេ បើយើងរៀនប៉ុណ្ណឹងចប់នោះ បើសិនកាលហ្នឹងចាប់យកវាមកប្រើការជាប់រហូតខ្ញុំប្រហែលជារួចខ្លួន ។

ដានី ៖ បើសិនជាពូប៉ាន់ស្មានមើលកាលយើងរៀនហ្នឹងជាថ្នាក់វិស្វករជាកម្មករជាន់ខ្ពស់ឬក៏យ៉ាងម៉េចម៉េចអាហ្នឹង?

សំអុន ៖ យើងរៀនកាលហ្នឹង យើងរៀនមិនដល់ឈ្មោះវិស្វករទេ អាំងស៊ីញេរទេ អាចត្រឹមថាអ្នកបច្ចេកទេសជួសជុល អ្នកបច្ចេកទេសជួសជុលបាន ទៅអាំងស៊ីញេរ ប្រហែលមិនទាន់រួចទេ ។

ដានី ៖ ចុះពូកាលនោះយើងរៀនពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ចឹង?

សំអុន ៖ បាទ!ពីច័ន្ទដល់សៅរ៍ ។

ដានី ៖ ចុះថ្ងៃអាទិត្យ?

សំអុន ៖ ថ្ងៃអាទិត្យយើងសម្រាកនៅផ្ទះ

ដានី ៖ នៅផ្ទះអត់មានធ្វើអីទេ?

សំអុន ៖ អត់មានធ្វើអីទេ អានសៀវភៅ អានអី បើគេមិនមកយកដើរលេងយើងនៅអានសៀវភៅនៅផ្ទះយើងទៅ ទំរៀនទំសូត្រទៅ ។

ដានី ៖ យើងអត់អាចដើរលេងខ្លួនឯងបាន ទៅទាក់ទងពីណាពីណីទេ?

សំអុន ៖ មិនបានទេ អត់បានទេ ព្រោះកន្លែងហ្នឹងមានរង្វង់គេចឹង មានរបងគេព័ទ្ធចឹងហ្នឹងហើយមានប៉ូលីសយាម ។

ដានី ៖ ប៉ូលីសយាម?

សំអុន ៖ បាទ!ប៉ូលីសយាមតាមនេះហ្នឹង ហើយយើងដើរៗតាមតារាងបាល់ទាត់ហ្នឹង តារាងបាល់ហ្នឹងដើរលេងដើរអី ហ្វឹកហ្វឺនហាត់រត់លេងអី គេលេងទៅពិនតាខ្ញុំអត់ដែលហាត់ប្រាណខ្ញុំមិនដែលធ្វើបាល់ខ្ញុំមិនដែលទះទេ អានតែសៀវភៅ ហើយពេលណាខ្លះគេឲ្យវាយអត្ថលីលេខសម្រាប់ចម្លងឯកសារចែកគ្នីគ្នាហ្នឹង ។

ដានី ៖ ចុះពួអ្នកដែលទៅហ្នឹងមានដែលទៅទាក់ទងនារីចិន មានសង្សារ មានប្រពន្ធអីនៅហ្នឹងដែរ?

សំអុន ៖ គ្មានសេរីភាពទេ ។

ដានី ៖ អត់មានទេ?

សំអុន ៖ បាទ!អត់មានទាល់តែសោះ ហើយក៏គ្មានអារម្មណ៍ថាទៅគិតអាអស់ហ្នឹងដែរ គ្មានទេ ។

ដានី ៖ ម៉េចចឹង?

សំអុន ៖ ទេ!ត្រូវតែចឹង ជំនាន់ហ្នឹងគេថាស្អាតស្អំ សូម្បីខ្ញុំប្រពន្ធនៅស្រុកព្រាត់គ្នា១០ឆ្នាំហើយ គ្រាន់តែនឹកក្នុងចិត្តទេ ឲ្យថានឹកនិយាយស្អីៗ ខ្ញុំមិនដែលនឹកនិយាយស្អីៗទេ ។

ដារ៉ា ៖ ចុះពេលទៅចិនហ្នឹង ពូមានបានជួបគ្រួសារពូមុននឹងឡើងអីទេ?

សំអុន ៖ អត់ទេ អត់មានបានជួបទេ ហើយអត់បានដឹងច្បាស់ដែរ អត់បានដឹងថាខ្ញុំទៅចិនច្បាស់ផង ។

ដារ៉ា ៖ ចឹងទៀត?

សំអុន ៖ ១០ឆ្នាំ គេអត់ប្តី ហើយខ្ញុំក៏អត់ប្រពន្ធដែរ ទៅជួបគ្នាវិញដោយសារតា សំ ប៊ិត ហ្នឹងគាត់យកទៅឲ្យខ្ញុំមកពីចិនវិញបានប៉ុន្មានខែ៣ខែដឹង គាត់ជួបខ្ញុំគាត់ថា អាអូន អាមុំនៅទេ ណាតិចយកប្រពន្ធទៀត ហើយខ្ញុំថា អ៊ឹងឯងថានៅយកឲ្យខ្ញុំមកចុះ ហើយក៏ហៅអ្នកទូរលេខគាត់ហ្នុងចុចមកតាបែមយើងនេះ យកប្រពន្ធឲ្យគេ ម៉ាភ្លែតហ្នឹងគេយកឲ្យខ្ញុំទាន់ចិត្តដែរ ពិនទំរាំទាន់

ចិត្តម៉ាខែបានជួបខ្ញុំ ដើរទៅដូចកង់រឺចឹង ហែលទឹកហែលអី ឡើងភ្នំ ដើរឡើងម៉ាខែ ខ្ញុំនៅកន្លែងទូរលេខហ្នឹង ខ្ញុំចាំបានអ្នកធ្វើទូរលេខសុទ្ធជាកូនសិស្សខ្ញុំទេ បងអ្នកម៉ោ ចេញស្មើរម៉ានប្រាប់ខ្ញុំម៉ោ ខ្ញុំដឹងចេញទៅថ្ងៃ១៣ ខែ៧ ឆ្នាំ១៩៨១ ហើយដល់ទៅដល់នោះថ្ងៃ១៥ខែ៨ ៨១ដែរ ពេលម៉ាខែ២ថ្ងៃ ម៉ាខែ២ថ្ងៃបានដល់ខ្ញុំ ។

ដានី : មួយខែ២ថ្ងៃ?

សំអុន : តាមមាថ្ងៃត្រូវប្រាប់ខ្ញុំរាយការណ៍ឲ្យខ្ញុំម្តង ព្រោះខ្ញុំនៅហ្នឹងហើយ ។

ដារ៉ា : ដូចយើងដើរចឹង យើងគេចអ្នកភូមិអ្នកអីចឹង?

សំអុន : បាទ!គេច គេអ្នកនាំទៅគេខ្លាចយួនដែលគេហៅយួនគេមែនហៅវៀតណាមទេ យើងអ្នកនៅនេះហៅវៀតណាម ។

ដានី : កាលហ្នុងពូមានកូនប៉ុន្មានហើយ?

សំអុន : កាលហ្នឹងខ្ញុំអត់បានជួបកូនខ្ញុំសោះ កូនខ្ញុំការហើយនៅនេះហើយ កូនខ្ញុំមានតែមួយទេកាលហ្នឹងមួយការនៅនេះទៀត កាលហ្នុងម៉ែវាចេញទៅកូនខ្ញុំអាយុ៥ឆ្នាំ នៅមួយយាយ មួយម្តាយក្មេកខ្ញុំ ម៉ែវាទៅតែម្នាក់ឯងទេ ទៅជួបខ្ញុំនោះ ទៅដល់ខ្ញុំនៅបានយូរណាស់ ខ្ញុំរត់ចេញពីខ្មែរក្រហមមកនៅមួយអន្តការយួនពាទ្រហើយបានដឹងថាកូនខ្ញុំការហើយពេលដែលជួបខ្ញុំ ៩២បានខ្ញុំពេលជួបខ្ញុំ ខ្ញុំត្រឡប់មកស្រុកវិញហើយ ស្គាល់គ្នាប្រវត្តិរឿងរ៉ាវខ្ញុំព្រាត់អីព្រាត់ពេក ប្រពន្ធកូនវេទនានៅតែខ្ញុំមួយម្នាក់ឯង ។

ដានី : ចុះពូកាលឆ្នាំ៨១ ពូមកពីចិនមកវិញកាលហ្នុងខ្មែរក្រហម?

សំអុន : រត់ទៅដល់ព្រំដែនអស់ហើយ ។

ដានី : ទៅដល់ព្រំដែនអស់ហើយយើងជិះអីពីចិនមកទៅ?

សំអុន : កាលមកលើកហ្នុងខ្ញុំជិះកប៉ាលទេ ។

ដានី : ជិះកប៉ាល់?

សំអុន : ជិះកប៉ាល់ ឡើងយប់ហើយកំពង់ផែនៅសៀមនៅថៃ តែមិនដឹងនៅកន្លែងណាទេ គេដឹកម៉ោតាមឡានហ្នឹងម៉ោឃុំបេទៀត ពួកអាកងចក្រគេដឹកម៉ោកាលហ្នុងកាត់ព្រៃម៉ោនៅភ្នំយើង នេះជួបមេខ្ញុំហ្នឹង ។

ដានី : ឈ្មោះ ទឹម សេង ហ្នឹង?

សំអុន : ទឹម សេង ។

ដានី : ទឹម សេង ក្រែងគាត់ទៅរៀននៅចិនដែរ?

សំអុន ៖ ទៅចិនដែរ គាត់ខាងកងទ័ព គាត់ម៉ោមួយទ័ពវិញម៉ោ ម៉ោមួយទ័ពគាត់យកកប៉ាល់ម៉ោ នៅតែខ្ញុំពួកខ្ញុំប៉ុន្មាននាក់នឹងទេនៅរៀនបច្ចេកទេសបន្ត ព្រោះអ្នករៀនបច្ចេកទេសហ្នឹងតាម អាណត្តិរបស់ចិនគេឲ្យរៀនតែបីឆ្នាំទេ ៣ឆ្នាំត្រូវឲ្យចប់ ពិនតែយើងនោះអត់បាន បានបីឆ្នាំ ហើយតែមិនទាន់ចប់ស្រួលបួលទៀត ។ ស្រុកកើតចឹងទៅហើយខ្ញុំក៏អត់បានរៀនសូត្រចឹងទៀត ក៏ចេះតែនៅធ្វើនេះធ្វើនោះខ្វះបានគេបញ្ជូនខ្ញុំមកនៅ ឃុនមីញ ឃុនមីញចិន ។

ដានី ៖ កាលហ្នុងជួបតាសេងនៅហ្នុងដែរអត់?

សំអុន ៖ នៅណា?

ដានី ៖ កាលនៅចិន កាលនៅឃុនមីញ?

សំអុន ៖ ឃុនមីញ គាត់ទៅម្តងដែរ ។

ដានី ៖ នៅម្តងដែរ?

សំអុន ៖ បាទ!គាត់ទៅម្តងជួបហើយក្រោយមកលែងបានជួបគាត់ហើយគាត់មកស្រុកវិញអស់ហើយ ។

ដារ៉ា ៖ ពេលរៀនសូត្រនៅចិន ពូមានខាងខ្មែរគេមានបំពាក់បំប៉ននគោលនយោបាយអីទេ?

សំអុន ៖ អត់មានទេ ។

ដារ៉ា ៖ ដូចឈ្មោះ ប៉ាវដែលជាប្រធាន?

សំអុន ៖ ប៉ាវ ហ្នឹងគេអត់មានទេ ។

ដារ៉ា ៖ ដូចជាកោះប្រជុំ ដូចជាវគ្គជានយោបាយ?

សំអុន ៖ អត់មានទេ អត់មានវគ្គជានយោបាយទេ ការប្រជុំគឺថាគិតទៅថាវគ្គបច្ចេកទេសទាំងអស់គិតតែពីរៀនសូត្រ ជឿនលឿនមិនជឿនលឿន ទៅមុខវឺថយក្រោយចឹង គិតតែប៉ុណ្ណឹងទេ ។

ដារ៉ា ៖ ហើយមានដឹងពីសភាពការណ៍យើងពីស្រុកខ្មែរអីម៉េចអីម៉េចទេ?

សំអុន ៖ កាលនោះខ្ញុំដឹងនៅក្នុងរោងចក្រ ដោយសារខ្ញុំលួចមើលកាសែតគ្រូ ហើយបានដឹង ដឹងក្រោយមកទូរទស្សន៍គេអត់ឲ្យមើលផង ។

ដារ៉ា ៖ អត់មានទូរទស្សន៍មើលទេ?

សំអុន ៖ មានទូរទស្សន៍មើល ពិនតែក្នុងបន្ទប់ទូរទស្សន៍យើងមិនបានឲ្យមើល មេយើងគេមិនបានឲ្យមើលមិនបានឲ្យផ្សាយអីទេ ដូច្នេះខ្ញុំក៏មិនចាប់អារម្មណ៍ មិនបាច់មើលក៏បានរៀនវិញល្អជាង ។

ដារ៉ា ៖ ពូនិយាយថាដឹងដំណឹងពីស្រុកខ្មែរយើងហ្នឹង ញ៉ឹកញាប់ទេ?

សំអុន ៖ មិនញាប់ទេ គាត់លាក់ដែរ គាត់លាក់ដែរ គ្រូគាត់លាក់គាត់ថាកុំបាច់ចង់ដឹងអី ខំរៀនសូត្រទៅស្រុកទេសមានគេគិតគូរហើយ ដឹងតាប៉ុណ្ណឹង គ្រាន់ខ្ញុំមើលដឹងថាវៀតណាមចូលស្រុកហើយ ។

ដានី ៖ ឆ្នាំ៦៩ហ្នឹង?

សំអុន ៖ បាទ!៧៩ហ្នឹង ខ្ញុំដឹងមើលកាសែត ។

ដារ៉ា ៖ នៅពេលពូបែកពី៧៦ដល់៧៩ ហ្នឹងក្នុងចន្លោះហ្នឹងពូអត់ដឹងពីសភាពការណ៍អីទេ?

សំអុន ៖ អត់ដឹង អត់ដឹងទេ ស្រុកខ្មែរម៉េចទេ អត់ដឹងថាយ៉ាងណាយ៉ាងណីទេ កាលខ្ញុំចេញទៅ ខ្ញុំនិយាយកាត់ប្រសាសន៍បន្តិចវាលើសពីសំភាសន៍ហើយ តែកាលខ្ញុំចេញទៅដូចសុខសប្បាយមាំណាស់តាមដែលខ្ញុំដឹង សុខសប្បាយគ្មានបញ្ហាអីថាយ៉ាងនេះយ៉ាងនោះអីអត់ទេ ។ ហើយខ្ញុំទៅនោះលែងដឹងអីទាំងអស់ដឹងតាប្រឹងរៀនសូត្រ តាមសំណូមរពររបស់មេៗខាងលើ ដែលសំណូមពរឲ្យយើងខំប្រឹងរៀនសូត្រហ្នឹងទៅ ហើយដល់ត្រឡប់មកវិញ បានខ្ញុំជួបកងទ័ពដែលនៅជុំគ្នានៅព្រំដែនហ្នឹង មកពីស្រុកចិនវិញខ្ញុំឲ្យខោអាវអស់ហើយខោអាវ ខ្ញុំមានម៉ាន វ៉ាឡូខ្ញុំឲ្យទាំងអស់ ខ្ញុំទុកតែខោមួយអាវមួយ ហើយខោចាស់មួយ អាវចាស់មួយ សម្រាប់ផ្លាស់ប្តូរប៉ុណ្ណឹង ។ តាប៉ុណ្ណឹងទេ ព្រោះឃើញម៉ោអាយ៉េអាយៃ៉ អាដេសអាដាសនិយាយប្រាប់តាំងពីរឿងអត់បាយរឿងអត់ទឹក អីកាលហ្នឹងខ្ញុំអត់ទាន់ជួបប្រពន្ធកូនខ្ញុំទេ ដល់ឃើញច្រើនពេកហ៊ីពិបាកវេទនាមែនទែន ។ ហើយខ្ញុំនៅឆ្ងល់ ដល់ពេលខ្ញុំម៉ោហ្នឹងគេបើកសាលារៀនសូត្រហា!ខ្ញុំវាឆ្ងល់ណាស់ ព្រោះខ្ញុំអញ្ចឹង ខ្ញុំសួរតិចកាលនេះគេមានថាស្អី សំណូមពរសួរកាលហ្នឹងគេបើកនយោបាយអំពីហេតុអាម៉េចបានវៀតណាមចូលស្រុកហើយយើងភៀសមកនៅព្រំដែនចឹង? និយាយច្រើនរៀបរាប់ច្រើនដើម្បីដោះស្រាយបញ្ហានឹងឲ្យចប់ គេឲ្យយើងសួរមានពាក់ព័ន្ធនឹងសំនួរអីណាខ្ញុំសួរបី“ខ” តែបី“ខ”ទីមួយហេតុអាម៉េចបានឲ្យប្រជាជនស៊ីបបរមួយហិតតា៣គោន កាលហ្នឹងមិនលើកថាម៉ាហិចតា៣គោនមែនទេ? ទីពីរទៀតហេតុម៉េចសម្លាប់មនុស្សអត់មានតុលាការកាត់ទោស ។ ទី៣ការចាត់ចែងមនុស្សបើផ្ញើកុម្មុយនីស្តដូចគេម៉េចក៏អត់មានពេលវេលា ចាត់ចែងពេលវេលាម៉ោងណាសម្រាកម៉ោងណាផ្ញើបី“ខ”ហ្នឹង ខ្ញុំបិះស្លាប់កាលហ្នុងពិនថាមិនអីមិនអីទេ ខ្ញុំពិនហ្នឹង ខ្ញុំនិយាយហើយចប់ហ្នឹងខ្ញុំមិនដែលចូលនយោបាយណាទៀតទេ ខ្ញុំដឹងតាបង្រៀនសិស្ស ។

ដារ៉ា ៖ ហេតុម៉េចបានជាពូអាចចោទចេញជាសំនួរបី“ខ”ហ្នឹងកើត?

សំអុន ៖ ខ្ញុំនឹកឃើញគេនិយាយគ្រប់គ្នាតាអញ្ចឹង ថាវ៉ៃមនុស្សចោល បានមិនដឹងប៉ុន្មានទេ ច្រើនណាស់ទ័ពក៏ខ្ញុំនិយាយ ទ័ពហ្នឹងមកប្រាប់ខ្ញុំផ្ទាល់ ប្រជាជនមិនសូវបានជួបទេ ព្រោះកន្លែងខ្ញុំ កន្លែងគេថាទ័ពកងពល ។ ហើយខ្ញុំចេញម៉ោបង្រៀនក្មេងបានជួបហ្នឹងណា ចេះតែនិយាយៗទៅហី!ដល់ចឹងហី!ស៊ីបបរស៊ីអីក៏ខ្ញុំមិនដឹងដែរក៏វាប្រាប់ដែរ កន្លែងខ្លះអត់មានបាយស៊ី ស៊ីតែបបរ

ស៊ីតិចតួចទៀត ។ ហើយពេលវេលាធ្វើអត់មានពេលម៉ោងពេលអីអត់សម្រាកទេ ចឹងបាន ខ្ញុំថាទៅសម្រាកម៉េច សម្រាកតែពេលស៊ីបាយហ្នឹង ហើយចឹងខ្ញុំសួរចឹងទៅ ហើយខ្ញុំសុំសួរ ដោយត្រង់មិនប្រាប់ថាត្រង់ៗខ្ញុំសួរហ្នឹងលើកសំណួរបី"ខ"ហ្នឹងហ្នឹង ។

ដាវ៉ា : មានអ្នកឆ្លើយទេពេលនោះ?

សំអុន : អត់ អត់ឆ្លើយថាអាហ្នឹងមកពីយួន គេនិយាយតាប៉ុណ្ណឹង ថាមូលហេតុទាំងអស់ហ្នឹងកើតមកពី យួនទេ យួនអ្នកបង្កភាពអុកឡុក បង្កើតទំនាស់ បង្កើនបញ្ហាក្នុងស្រុកទេសយើងហ្នឹងមែនទេ រឿងខាងគេហ្នឹងសម្លាប់មនុស្សអីទេ គឺពេលខ្វះគេយកយួនធ្វើលេសទាំងអស់ហ្នឹង ហើយរឿង ហ្នឹងពាក់ព័ន្ធម៉េចខ្ញុំមិនដឹងទេ សង្គ្រាមអស់ហ្នឹង ខ្ញុំមិនបានពាក់ព័ន្ធសោះ ។

ដានី : ចុះពូ ពូស្គាល់ សំ ប៊ិត ស្គាល់តាំងពីអង្កាល់មក?

សំអុន : ខ្ញុំលឺឈ្មោះយូរហើយ ពិនម្យ៉ាងស្រុកគាត់នៅនេះ ប្រពន្ធខ្ញុំគាត់ធ្លាប់ស្គាល់ ម៉ែឪម្ដាយក្មេកខ្ញុំ គាត់ក៏ធ្លាប់ស្គាល់ ដូច្នេះខ្ញុំមិនស្គាល់គាត់ច្បាស់ទេ គាត់គ្រាន់តែស្គាល់ឈ្មោះ ហើយគាត់ក៏ ស្គាល់ឈ្មោះខ្ញុំដែរ ខ្ញុំគ្រាន់តែគ្រួសារកូនប្រសារម៉ែក្មេកខ្ញុំហ្នឹង ។

ដានី : ប៉ុន្តែកាលឆ្នាំ៨១ ពូមានប្រសាសន៍ថាពូជួបគាត់នៅព្រំដែន?

សំអុន : ជួប ជួបគាត់នៅព្រំដែន ។

ដានី : ជួបទៅគាត់ស្គាល់ពូហ្នឹង?

សំអុន : ស្គាល់ ស្គាល់ខ្ញុំ ព្រោះគាត់ម៉ោនៅហ្នឹងម៉ានថ្ងៃបាន បានជួបខ្ញុំហ្នឹង ជួបខ្ញុំដឹងថាខ្ញុំឈ្មោះចឹង គ្រួសារខ្ញុំឈ្មោះចឹង កូនប្រសារយាយហ្នឹងចឹងអីណា ហើយយាយម៉ែក្មេកខ្ញុំគាត់ថាស្គាល់ ច្បាស់ពេកហើយ បាននៅស្រុកភូមិនឹងគ្នា ស្គាល់គាត់ប្រាប់ថាអាមុំនៅទេណា តិចយកប្រពន្ធ ទៀតទៅ ខ្ញុំថាបើនៅ យកឲ្យខ្ញុំម៉ោ ម៉ាភ្លែតឲ្យចុចទូរលេខភ្លាម ឲ្យចុះក្រោមឲ្យយកប្រពន្ធឲ្យគេ ភ្លាមបានដូចចិត្ត ។

ដានី : កាលហ្នឹង សំ ប៊ិត គាត់ធ្វើអី?

សំអុន : ភូមិភាគ ។

ដានី : គាត់ភូមិភាគណា?

សំអុន : ភូមិភាគនិរតីហ្នឹង ។

ដានី : កាលពីឆ្នាំ?

សំអុន : ៨១ហ្នឹង ។

ដានី : ៨១ហ្នឹង?

សំអុន ៖ បាទៗ ។

ដានី ៖ ចុះមុនឆ្នាំ៨១?

សំអុន ៖ អត់ដឹង ។

ដានី ៖ អត់ដឹង?

សំអុន ៖ បាទ!ដឹងនៅណានៅណីទេ ខ្ញុំនៅស្រុកចិនហ្នឹង ហី!នៅណាខ្ញុំនៅហ្នឹងហើយ សូម្បីតាខ្ញុំនៅនេះ ប្រពន្ធខ្ញុំក៏ថាដែលថាខ្ញុំមិនដែលដើរទៅណា កុំសួរតាមផ្លូវថាមានស្អីអត់ដឹងទេ ។

ដានី ៖ ចុះពូស្គាល់តាមុត តាំងពីអង្កាល់មក?

សំអុន ៖ ខ្ញុំស្គាល់តាំងពីពល៣ តាំងពីនៅកំពង់សោមមក ។

ដានី ៖ ចុះពេលមុនហ្នឹង?

សំអុន ៖ អត់ដឹង ។

ដានី ៖ ចុះកាលពីសម័យឆ្នាំ៧០ ៧០អីហ្នឹងមានដែលជួបគាត់ទេ?

សំអុន ៖ អត់ដឹង អត់ដែលជួប ។

ដានី ៖ អត់ដែលជួបទេ?

សំអុន ៖ បាទ!អត់ដែលជួប អត់ដែលស្គាល់ទៀត ។

ដានី ៖ អត់ដែលស្គាល់គាត់ទេ?

សំអុន ៖ បាទ ។

ដានី ៖ ក្រែងស្រុកកំណើតគាត់នៅម្តុំៗនេះដែរ?

សំអុន ៖ ម្តុំនេះនៅស្រែក្នុងនេះ ។

ដានី ៖ នៅណា?

សំអុន ៖ នៅស្រែក្នុង ។

ដានី ៖ នៅស្រែក្នុង?

សំអុន ៖ ស្រែក្នុង បាទ!ស្រែក្នុង ព្រៃខ្មៅអី ។

ដានី ៖ ប៉ុន្តែពូមិនដែលឃើញគាត់ទេ?

សំអុន ៖ មិនដែលឃើញទេ ។

ដានី ៖ ចឹងពូបានជួបគាត់ហ្នឹងជួបតែពេលពូនៅកំពង់សោមទេ? ពេលឆ្នាំ៧៥ហ្នុង?

សំអុន ៖ បាទ!នៅកំពង់សោម ឃើញគាត់ដើរគាត់អី ជួបម្តងជួបនៅថ្នល់អាទេះភ្លើងដែរ កាលខ្ញុំជួស ជុលថ្នល់អាទេះភ្លើងហ្នឹង មកនៅកំពង់សោម ហើយគាត់ទៅជិះអាទេះភ្លើងនឹងដែរ ។ ហើយ

ខ្ញុំក៏ជិះមួយគាត់ហ្នឹង ជិះមួយគ្នាច្រើន យើងជួសជុលហើយហឺ!ណា ជិះឡើងពីត្រពាំងល្ពៅ កំពតហ្នឹង ជិះមកមើលអាផ្លូវណាស្រួលអត់អាយើងធ្វើហ្នឹងណា ។

ដានី : គាត់និយាយអីខ្លះ?

សំអុន : គាត់អត់មាននិយាយអីផងអត់មានបានលឺគាត់និយាយអីទេ គ្រាន់តែសើចញ៉ឹមៗដាក់គ្នាហ្នឹង ។

ដានី : ចុះឆ្នាំ៨១ ពេលពូមកដល់ព្រំដែនហ្នឹងជួបគាត់ទៀតទេ?

សំអុន : ៨១ អត់ដែលជួបទេ មិនដែលជួបគាត់ទេនៅព្រំដែន ។

ដានី : ចឹងពូឆ្នាំ៨១ ពូមកនៅកន្លែងថ្មដាហ្នឹង មកនៅកងពលទី៣របស់តាសេង?

សំអុន : បាទ!តាសេងហ្នឹងហ្មង ។

ដានី : កាលហ្នឹងកងពលទី៣ ចាប់ពីកន្លែងណាដល់កន្លែងណាដែរ?

សំអុន : តាំងពីថ្មដាហ្មងមកត្បូងគេហៅកោះកុង កោះកុងហ្មងមិនចេះជិត ។

ដានី : មកខាងកោះកុងវិញ?

សំអុន : បាទ!កោះកុងវិញ ។

ដានី : ចុះពីថ្មដាទៅសំឡូត?

សំអុន : សំឡូតនៅខាងពល២ ខាងតាវ៉ែម វិញ ។

ដានី : តាវ៉ែម វិញ?

សំអុន : បាទ!ហ្នឹងតាវ៉ែម ។

ដានី : ពូនៅជាមួយតាសេង បានរយៈពេលប៉ុន្មានដែរ?

សំអុន : ខ្ញុំនៅហ្នឹងយូរដែរហ្នឹង យូរម៉ោតាំងពី៨១ដល់៨៥-៨១ខ្ញុំម៉ោ ខ្ញុំបានកូន២ ហើយបានខ្ញុំគេចចេញមានអង្គការគេមក អង្គការយូអ៊ិនហ្គោមុនដំបូងចេះតែ នៅមួយគាត់ម៉ាំរយៈប្រពន្ធខ្ញុំទៅហ្នឹងរៀបចំផ្ទះសំបែងអីស្រួលបួលផ្ទះខ្ញុំផ្ទះធ្វើធំណាស់កាលហ្នឹងសសរប៉ុនៗនេះសរសរគគីចុះស្រុកហ្មងខ្លះអីឈើ ។ ដល់ធ្វើផ្ទះអីហើយចឹងគ្រាប់ផ្លោងវៀតណាមវាយចូលហ្នឹង វ៉ៃចូលដកម៉ាឃ្លាចឹងខ្ញុំរៀបរត់ម៉ាសារទៅនៅមួយអង្គការយូអ៊ិនហ្គោ រត់ទៅអត់រួចគាត់ឲ្យកូនឡានអាហ្ស៊ីបហ្នឹងទៅដឹកខ្ញុំយកម៉ោមន្ទីរវិញ ។ យកខ្ញុំទៅយកមកណោះវិញយកមកនាំប្រពន្ធនាំកូនមកវិញមកនៅបានមួយរយៈផ្លោងទៀត ។ បានប៉ុន្មានខែទេ មួយឆ្នាំទេដឹងផ្លោងទៀត រត់បានមកកើតតិចទៀត កើតតិចទៀតហ្នឹងបានជួបអង្គការយូអ៊ិនហ្គោ ហើយគេចរចារគ្នាថាអាឡូវគេជួយពីរយ៉ាង អាឡូវថាម៉ាខាងខ្មែរក្រហមគ្រប់គ្រងខាងនយោបាយ ខាងគេជួយនឹងឧបភោគបរិភោគ ។ ដូច្នេះគេថាការពារជនភៀសខ្លួន ថាកុំឲ្យយ៉ាប់យ៉ឺនពេក ថានៅនោះ

ខ្មែរក្រហមដាច់ម៉េច ខ្វាចប្រជាជនអត់បាយហូប អង្គការគេពិភាក្សាគ្នាថាខាងខ្មែរក្រហមនេះគ្រប់គ្រងខាងនយោបាយចុះ ខាងយូអ៊ិនហ្កគ្រប់គ្រងខាងឧបភោគបរិភោគហ្នឹង ហើយនៅហ្នឹងបានពាក់កណ្ដាលម្នាក់ខ្ញុំនៅធ្វើជាគ្រូបង្រៀនដែរ ។ គេអត់មានឲ្យមកវិញហើយ លែងធ្វើទ័ពធ្វើអី លែងនៅកងពលទៀត ។ ហើយដាច់ម្ទិត ហ្នឹងនៅមួយពេទ្យម្ដង បាននៅពេទ្យនៅមួយពេទ្យហ្នឹង ពេទ្យកងពលដែរ ពិនជាអត់មាននៅមួយកងពលធំទៀតទេ ។

ដានី ៖ ចុះពូពី៨១ មកនៅកន្លែងកងពលពូមានតួនាទីអីទៅ?

សំអុន ៖ ខ្ញុំ ។

ដានី ៖ បាទ ។

សំអុន ៖ ខ្ញុំអត់មានអីសោះ អត់អាលីងគេមិនដែលចាត់តាំងថាខ្ញុំធ្វើអីធ្វើអីគេទេ គឺខ្ញុំគេឲ្យតែបង្រៀនតែក្មេងគ្រូ កូនសិស្សខ្ញុំប៉ុនៗនេះធំៗណាស់ ។

ដានី ៖ អត់ទេ កាលហ្នឹង ក្រែងតាសេង គាត់ថាហៅពូមកនៅជាមួយ?

សំអុន ៖ មកនៅជាមួយនៅធ្វើអីនៅធ្វើតែស្មៀន មកសរសេរអីតែចឹង ចុះតែកំណត់ហេតុចុះតែអីៗ របាយការណ៍អីផ្សេងៗធ្វើតែប៉ុណ្ណឹង គាប៉ុណ្ណឹងទេ ថាឲ្យខ្ញុំឈ្មោះអី អត់មានទេ អត់មានឋានៈនាទីអី នៅតែចឹងហ្នង ពេលខ្លះពេលយប់ព្រលប់អីហ្នឹង គាត់នេះឃើញខ្ញុំធ្វើការយប់អីហ្នឹង ពីរនាក់បងធិន ឈ្មោះបងធិន គាត់អនុប្រធានមន្ទីរ ។

ដានី ៖ អនុប្រធានមន្ទីរកងពល?

សំអុន ៖ បាទ!កងពល ពីរនាក់ហ្នឹងនៅហ្នឹង ។

ដានី ៖ ប្រធានមន្ទីរណាគេ?

សំអុន ៖ ប្រធានមន្ទីរតានឿន

ដានី ៖ ពូអាចថាមានតួនាទីជាគណៈមន្ទីររឺកងពលអីទេ?

សំអុន ៖ អត់ទេ អត់មានឈ្មោះ ។

ដានី ៖ អត់ទេ?

សំអុន ៖ អត់មានស្អីសោះ ខ្ញុំអត់អាលីងផង ។

ដានី ៖ ចឹងចុះពូម៉េចដូចថាតា ប៊ិត គាត់មកពូបញ្ញោគេឲ្យ?

សំអុន ៖ គាត់ស្គាល់ចឹងហ្នងថាកន្លែងហ្នឹង កន្លែងហ្នឹងដូចថាខ្ញុំធ្វើគ្រូគេមួយមុខទេគ្រូ បាទ!ម៉ាមុខគត់ធ្វើគ្រូគេ ឲ្យខ្ញុំថាមានអំណាចមាននាទី តំណែងអីអត់សោះ ពិនថាប្រហែលជាមនុស្សទាំងឡាយ

ប្រហែលជាស្គាល់ខ្ញុំ ។ បានអ្នកខ្លះគេគោរពរាប់អានទៅ អ្នកខ្លះគេស្រឡាញ់រាប់អានទៅ បាទ! វាមានពីរយ៉ាងចឹង អ្នកធំៗគេស្រឡាញ់គេរាប់អានទៅ អ្នកតូចៗគេគោរពគេរាប់អានទៅ ។

ដានី ៖ តាសេង ហើយតាវ៉ែម កូនប្រសារតាម៉ុកបងប្អូនគាត់?

សំអុន ៖ បាទ!បងប្អូន ។

ដានី ៖ បងប្អូនយ៉ាងម៉េច?

សំអុន ៖ បងប្អូនបង្កើត ។

ដានី ៖ បងប្អូនបង្កើត?

សំអុន ៖ បាទ ។

ដានី ៖ ពីណាបងពីណាប្អូន?

សំអុន ៖ បងសេងបង ។

ដានី ៖ តាសេងបងតាវ៉ែម?

សំអុន ៖ បាទ!បងសេង ខ្ញុំហៅបង បងសេង បងបង្កើត ។

ដានី ៖ បងប្អូនបង្កើត?

សំអុន ៖ ព្រោះតាវ៉ែមកូនតាម៉ុក តាវ៉ែមកូនប្រសារតាម៉ុក ច្បាស់ណាស់ ។

ដានី ៖ ចុះតាសេងគាត់ស្លាប់ឆ្នាំណា?

សំអុន ៖ អត់ដឹងដែរ ។

ដានី ៖ ពេលឆ្នាំ៨៥ ពូទៅនៅជាមួយអង្គការយូអ៊ិនហ្គោ ហ្នឹងគាត់នៅទេ?

សំអុន ៖ នៅគាត់ទៅលេង ។

ដានី ៖ គាត់ទៅលេងដែរ?

សំអុន ៖ បាទ!ទៅលេងនៅរោងនៅជំរំហ្នឹង ជំរំសាយខេ គេហៅសាយខេតាំ ។

ដានី ៖ ចុះពូអត់ដឹង អត់ដែលលឺដំណឹងថាគាត់ស្លាប់ទេ?

សំអុន ៖ អត់ដឹង អត់ដឹងថាម៉េចទេ លែងដឹងលែងលឺអស់ហើយ ។

ដានី ៖ លែងដឹងហើយ?

សំអុន ៖ បាទ!ស្អីក៏ខ្ញុំលែងដឹងដែរ ព្រោះខ្ញុំធ្វើម៉េចឲ្យបានគេចរួចពីហ្នុងមក ខ្ញុំអត់ស្អប់ទេ ព្រោះខ្ញុំមិនដែលលំបាក គេមិនដែលធ្វើបាបអីខ្ញុំ ក៏ប៉ុន្តែខ្ញុំអត់ចូលចិត្តនៅ ខ្ញុំនិយាយត្រង់ជំរាបតាមត្រង់ គ្រូខ្ញុំឃើញសង្គ្រាមធុញណាស់ ។ បើក្រៅពីខ្ញុំប្រហែលជាគេសម្លាប់ខ្ញុំចោល ព្រោះខ្ញុំរត់ចូលថៃម្តងហើយ ប្រមូលដៃគូរខ្ញុំនៅកងពលប្រហែលមួយកងពលទៅ ហើយអង្គរក្សគេប៉ុន្មានទៅហ្នឹង

ឃើញគេទៅយកមកវិញអស់ប៉ុន្មានតាំឡឹង ពិនកង់ពលត្រូវគេសម្លាប់ចោលហើយប្រធានអត់តែខ្ញុំទេ ។

ដានី ៖ ចុះពូមកនៅស្រុកវិញឆ្នាំណាដែរពូ?

សំអុន ៖ ខ្ញុំម៉ោ៩២ ថ្ងៃ២៧ខែ៧ទៀត៩២ខ្ញុំចេញមកពីជុំរំ មកនៅអីស្នឹកប់ស្រូវនេះចេញមក ហ្នឹងមកដល់ហ្នឹងម៉ង់ បានមកដល់ហ្នឹង ។

ដារ៉ា ៖ មកតាមអាកម្មវិធីជនភៀសខ្លួនហ្នឹង?

សំអុន ៖ ជនភៀសខ្លួន បាទ! ជនភៀសខ្លួនហ្នឹងមិនមែនពួកផ្តាច់ខ្លួនទេ ខ្ញុំជនភៀសខ្លួន ។

ដារ៉ា ៖ កាលឆ្នាំ៩២?

សំអុន ៖ បាទ!ឆ្នាំ៩២នេះគេហៅថាមាតុភូមិនិវត្តន៍ ។

ដារ៉ា ៖ នៅណានៅភូមិណាអីភូមិណា ចូលភូមិហ្នឹងវិញ?

សំអុន ៖ បាទ!ហើយខ្ញុំមកនេះបាតដៃទទេរទេ ពិនបានមកដល់រដ្ឋាភិបាលចែកដីកាលហ្នឹងរដ្ឋ កម្ពុជាចែកដីបានតិចទៅ ខ្ញុំបានធ្វើការជាមួយអ៊ុនគាត់បានតិចមក កាលហ្នឹងនៅភីអូរេស៊ីដង់ អាហាររមួយខែបាន៤០០ កាលហ្នុងលុយនៅថ្លៃ៤០០ បាន២ខែគត់ ដាច់អាណត្តិអ៊ុនគាត់ហ្នឹងទៅបានអាលុយហ្នឹងម៉ោឲ្យម៉ែវាទិញស្រូវទិញស្រែខ្វះទិញគោអីខ្វះ ចែកកូនចែកចៅរហូតទល់អាឡូវ ព្រោះកិច្ចការទៀតខ្ញុំអត់ចេះធ្វើអីទេ ស្រែក៏មិនចេះធ្វើ ឈើក៏មិនកាប់ចប់ហើយខ្ញុំ ។

ដានី ៖ ចុះពូមកដល់សព្វថ្ងៃនេះពូដែលលឺពត៌មានអីដែលទាក់ទងនឹងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមអីទេ?

សំអុន ៖ ខ្ញុំចាំស្តាប់ដែរ ពិនតែលឺសូរថា នៅតាចឹង នៅតែកាត់ទោសខ្មែរក្រហម មិនដឹងថាកាត់របៀបណាធ្វើយ៉ាងម៉េចទៀត ដោះស្រាយយ៉ាងម៉េច ខ្ញុំអត់ថាទិសដៅរបស់តុលាការហ្នឹងគាត់មានយ៉ាងណា ខ្ញុំអត់ដឹងទេ លែងដឹងហើយអាហ្នឹង ថ្នាក់កំពូល១ទុកឲ្យលោកនេះ ហើយលោកគ្រូអីដឹងលឺជួយផ្សាយ ទៅខ្ញុំមិនបានដឹង ។

ដានី ៖ ពូអត់ដឹងថាមកដល់សព្វថ្ងៃហ្នឹងគេវិវត្តន៍ដល់ណាគេកាត់ទោសបានពីណាពីណីអីទេ ពូអត់ដឹង?

សំអុន ៖ អត់ដឹង ។

ដានី ៖ អត់ដឹងទេ?

សំអុន ៖ អត់ ។

ដារ៉ា ៖ ពូមានវិទ្យុស្តាប់?

សំអុន ៖ អត់ ។

ដារ៉ា ៖ ទូរទស្សន៍?

សំអុន ៖ ទូរទស្សន៍មាន ខ្ញុំគ្រាន់តែដឹងថាមេធំៗ ខៀវ សំផន តាម៉ុក ណាទៀត អៀង សារី ណាទៀតទេនៅក្នុងហ្នឹង ដឹងដែលថាពេលកាត់ទោស អៀង ធីរិទ្ធ ក្នុងនេះហ្នឹងខ្ញុំក៏បានមើលឃើញដែរ ឃើញតែរូបថត រូបអីហ្នឹង ខ្ញុំមិនសូវស្គាល់ខ្លះក៏ចាស់ដែលហើយ ខ្ញុំមើលឃើញរូបថតហ្នឹង។ រូបថតរូបអីហ្នឹងខ្ញុំអត់ដែលបានមើលចឹងទេ អរគុណលោកគ្រូបានឲ្យមើលចាំមើលចង់ដឹងដែរហ្នឹង ខ្ញុំក៏អត់មានវិទ្យុស្តាប់ ទូរទស្សន៍ក៏វាអត់គ្រប់គ្រាន់ អត់គ្រប់គ្រាន់ទេ។

ដារ៉ា ៖ ខ្ញុំដូចជាអស់អីសួរហើយពូ?

សំអុន ៖ បាទៗ ។

ដានី និងដារ៉ា ៖ បាទ!អរគុណលោកពូច្រើនដែលចំណាយពេលផ្តល់បទសំភាសន៍ជាមួយពួកខ្ញុំបាទ!ខ្ញុំអរគុណច្រើនលោកពូ ។

សំអុន ៖ បាទៗ ។

**-ចប់-**